# រាជរដ្ឋាភិបាលកម្ពុជា

## គោលនយោបាយ

ស្តីពី

# ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

# ២០២០-២០៣០

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## អារម្ភកថា

ការដាក់ចេញឱ្យអនុវត្ត "**គោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ២០២០-២០៣០**" នេះ គឺជាផ្នែកមួយនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ នៅក្នុង**មុំទី ៤** "***ការធានានិរន្តរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ***" នៃចតុ-**កោណទី ៤** "***ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន***" ។

កម្ពុជាបានអនុវត្តដោយជោគជ័យនូវយុទ្ធសាស្ត្រចតុកោណទាំងបីដំណាក់កាល ព្រមទាំងបាននិងកំពុងបន្តអនុវត្តប្រកបដោយជោគជ័យនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា ។ ស្របពេលដែលកម្ពុជារក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងអត្រាប្រចាំឆ្នាំជាមធ្យមលើសពី ៧% ក្នុងរយៈពេលជាងមួយទសវត្សរ៍ចុងក្រោយ, ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ត្រូវតែរក្សាឱ្យបាននូវតុល្យភាពជាមួយនឹងការគាំពារបរិស្ថាន ដើម្បីធានានិរន្តរភាព និងបរិយាប័ន្ន ។ ទន្ទឹមនឹងល្បឿនយ៉ាងឆាប់រហ័សនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ដែលនាំឱ្យមានកំណើនឆាប់រហ័សនៃនគរូបនីយកម្ម, ការកែប្រែ និងលើកកម្ពស់ជីវភាព និងភាពកាន់តែសម្បូរបែបនៃការរស់នៅរបស់ប្រជាជនកម្ពុជា បាននិងកំពុងប្រឈមនឹងបញ្ហាជាផលវិបាកត្រឡប់មកវិញផងដែរ គឺល្បឿននៃកំណើនសំរាម សំណល់រឹងទីប្រជុំជនដែលបាននិងកំពុងកើនឡើងក្នុងសន្ទុះមួយគួរឱ្យកត់សម្គាល់ និងត្រូវមានការយកចិត្តទុកដាក់ខ្ពស់ ។

អាស្រ័យហេតុនេះ រាជរដ្ឋាភិបាល មានភាពចាំបាច់ត្រូវដាក់ចេញឱ្យអនុវត្តនូវ "**គោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ២០២០-២០៣០**" ដែលមានចក្ខុវិស័យ "***រួមចំណែកធ្វើឱ្យព្រះរាជាណាចក្រកម្ពុជាកាន់តែមានបរិស្ថានស្អាត ការរស់នៅប្រកបដោយផាសុកភាព សុខុមាលភាព និងសោភ័ណភាពទាក់ទាញ សមស្របទៅនឹងកំណើននគរូបនីយកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ចដ៏ឆាប់រហ័ស***" និង មានគោលបំណង "***រៀបចំបង្កើត និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនមានលក្ខណៈទំនើប, គ្រប់ជ្រុងជ្រោយ, ដោយគិតគូរអំពីប្រសិទ្ធភាពសេដ្ឋកិច្ច, លទ្ធភាពធនធានហិរញ្ញវត្ថុ, និរន្តរភាពបរិស្ថាន និងទិដ្ឋភាពសង្គម ។***"

ជាការពិតណាស់ ការដែលគ្រាន់តែបង្កើតបាននូវប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយប្រសិទ្ធភាព និងភាពគ្រប់ជ្រុងជ្រោយ គឺនៅមិនទាន់មានភាពគ្រប់គ្រាន់នៅឡើយទេសម្រាប់បុព្វហេតុនៃកិច្ចគាំពារបរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន ប៉ុន្តែជាចាំបាច់ត្រូវមាន

ការចូលរួមយ៉ាងសកម្ម ប្រកបដោយស្មារតីភ្ញាក់រលឹក និងការទទួលខុសត្រូវខ្ពស់, ការផ្លាស់ប្ដូរឥរិយាបថ, ទម្លាប់, របៀបរបបរស់នៅ, របៀបរបបនៃការធ្វើអាជីវកម្ម-ផលិតកម្ម ព្រមទាំងការយល់ដឹងរបស់គ្រប់តួអង្គ និងភាគីពាក់ព័ន្ធទាំងអស់ដែលជាអ្នកបង្កើតសំរាម សំណល់រឹងទីប្រជុំជន ដោយត្រូវអនុវត្តគោលការណ៍សកល **៣អ៊ែរ** (3Rs): **កាត់បន្ថយ** (Reduce) **ប្រើប្រាស់ឡើងវិញ** (Reuse) និង **កែច្នៃ** (Recycle) ហើយត្រូវចាត់ទុកថា "**សំណល់ជាធនធាន**" រីឯ "**អ្នកបង្កើតសំរាមមានភារកិច្ចបង់ថ្លៃសេវា**" ។

រាជរដ្ឋាភិបាល នឹងតាមដានដោយយកចិត្តទុកដាក់លើដំណើរការអនុវត្តគោលនយោបាយស្ដីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននេះ ដែលអាចចាត់ទុកបានថាជាសមរភូមិកែទម្រង់ថ្មីមួយ តាមរយៈយន្តការតាមដានត្រួតពិនិត្យ, កែតម្រូវ និងវាយតម្លៃលើការអនុវត្ត ដើម្បីធានាប្រសិទ្ធភាព, ប្រសិទ្ធផល និងតម្លាភាពនៃការអនុវត្ត ដែលជាផ្នែកដ៏សំខាន់ក្នុងការធានាតុល្យភាពរវាងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងការគាំពារបរិស្ថាន ព្រមទាំងការឆ្លើយតបទៅនឹងទស្សនវិស័យស្ដីពីនិរន្តរភាព បរិស្ថានទីក្រុងដែលបាននិងកំពុងអនុវត្តក្នុងតំបន់អាស៊ាន ក៏ដូចជាការរួមចំណែកដល់ការងារប្រឡងប្រណាំងទីក្រុងស្អាតនៅថ្នាក់ជាតិ និងក្រោមជាតិផងដែរ ។

តាមរយៈការអនុវត្តគោលនយោបាយនេះ រាជរដ្ឋាភិបាលរំពឹងថា ចាប់ពីពេលនេះដល់ឆ្នាំ ២០៣០ ខាងមុខ សំរាម សំណល់រឹងទីប្រជុំជនគ្រប់ប្រភេទនឹងត្រូវបានញែក, វេចខ្ចប់, ទុកដាក់, សម្អាត, ប្រមូល, ដឹកជញ្ជូន, ប្រើប្រាស់ និងកែច្នៃ ព្រមទាំងធ្វើប្រព្រឹត្តិកម្ម តាមបច្ចេកវិទ្យាប្រកបដោយអនាម័យ និងសុវត្ថិភាពបរិស្ថាន ។ ជាមួយគ្នានេះផងដែរ ការអនុវត្តគោលនយោបាយនេះនឹងជួយលើកតម្កើងនូវសុខុមាលភាពប្រជាជន, លើកកម្ពស់ និងកែលម្អសោភ័ណភាពទីប្រជុំជន, រាជធានី, ក្រុង និងស្រុក ឱ្យកាន់តែមានភាពទាក់ទាញថែមទៀត ជាពិសេសលើកស្ទួយកិត្យានុភាពជាតិស្របតាមពាក្យស្លោក "**កម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ**" ។

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមសំដែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ ចំពោះក្រុមការងារអន្តរក្រសួងក្រោមការដឹកនាំ និងសម្របសម្រួលរបស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានរៀបចំ "**គោលនយោបាយ ស្ដីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ២០២០-២០៣០**" ដ៏មានសារសំខាន់នេះ និងសូមវាយតម្លៃខ្ពស់លើការចូលរួមពីគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងដៃគូអភិវឌ្ឍន៍ដែលបានគាំទ្រ និងផ្ដល់កិច្ចសហការចំពោះកិច្ចខិតខំប្រឹងប្រែងរួមគ្នា រៀបចំគោលនយោបាយ នេះឡើង ។

ខ្ញុំសូមណែនាំឱ្យ ក្រសួង-ស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាល ប្រកាន់ខ្ជាប់នូវអភិក្រមការងារប្រកបដោយបុរេសកម្ម និងសកម្ម ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីធានាបាននូវភាពជោគជ័យនៃការអនុវត្តគោលនយោបាយនេះ ។ រាជរដ្ឋាភិបាល នឹងផ្ដល់ការលើកទឹកចិត្តដល់ភាគីពាក់ព័ន្ធដែលនឹងរួមចំណែកដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជននេះ ។ ជាមួយគ្នានេះ ខ្ញុំសូមស្នើប្រជាជនកម្ពុជាគ្រប់រូប, ដៃគូអភិវឌ្ឍន៍ និងតួអង្គពាក់ព័ន្ធទាំងអស់ សកម្មចូលរួមអនុវត្ត

គោលនយោបាយនេះ និងប្រកាន់ខ្ជាប់នូវកាតព្វកិច្ចជាពលរដ្ឋល្អក្នុងការចូលរួមថែរក្សា អភិរក្សបរិស្ថាន ក្រោមពាក្យស្លោក "**កម្ពុជាស្អាតផ្តើមចេញពីយើងម្នាក់ៗ**" ដែលជាបុរេលក្ខខណ្ឌកំណត់ភាពជោគជ័យនៃសមរភូមិកែទម្រង់ និងការដ្ឋានការងារថ្មីមួយនេះ ។

ថ្ងៃអង្គារ ៥ កើត ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ខ្លឹមសារសង្ខេប
# ឯកសារគោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
# ២០២០-២០៣០

ក្នុងរយៈពេលជាងមួយទសវត្សរ៍កន្លងមកនេះ កម្ពុជាសម្រេចបាននូវសមិទ្ធិផលយ៉ាងធំធេង ជាពិសេសការរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដោយធានាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងកម្រិត អត្រាប្រចាំឆ្នាំជាមធ្យមលើសពី ៧%, បានប្រែក្លាយខ្លួនជាប្រទេសមានចំណូលមធ្យមកម្រិតទាបកាលពីឆ្នាំ ២០១៥ និងកំពុងឈានឡើងក្នុងជំហានរឹងមាំឆ្ពោះទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងប្រទេសចំណូលខ្ពស់នៅឆ្នាំ ២០៥០ ។ ការរីកចម្រើនក្នុងសន្ទុះខ្ពស់ និងឆាប់រហ័សបែបនេះ ប្រព្រឹត្តទៅបានដោយសារកត្តាសន្តិភាព, ស្ថិរភាពនយោបាយ, សុវត្ថិភាពទូទាំងប្រទេស និងមាគ៌ាអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចដ៏ត្រឹមត្រូវ ដែលកម្ពុជាសម្រេចបានប្រកបដោយជោគជ័យ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងទស្សនវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** ។

ទន្ទឹមនឹងល្បឿនយ៉ាងឆាប់រហ័សនៃការអភិវឌ្ឍប្រទេស និងការរីកចម្រើននៃកម្រិតជីវភាពរស់នៅរបស់ប្រជាជន កម្ពុជាបាននិងកំពុងប្រឈមបញ្ហាជាផលវិបាកត្រឡប់មកវិញផងដែរ គឺល្បឿននៃកំណើនសំរាម សំណល់រឹងទីប្រជុំជន ដែលបាននិងកំពុងកើនឡើងក្នុងសន្ទុះមួយគួរឱ្យកត់សម្គាល់ និងត្រូវមានការយកចិត្តទុកដាក់ខ្ពស់ ។

រាជរដ្ឋាភិបាល នីតិកាលទី ៦ នៃរដ្ឋសភា បានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នៅក្នុងមុំ **ទី៤** ***"ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ"*** នៃ **ចតុកោណ ទី៤** ***"ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន"*** ដោយផ្តោតអាទិភាពលើការបន្តពង្រឹងការគ្រប់គ្រង សំណល់រឹង, រាវ, ឧស្ម័ន និងសារធាតុគ្រោះថ្នាក់ តាមរយៈការអនុវត្តគោលការណ៍សកល **"៣អ៊ែរ" (3Rs)** រួមមាន៖ កាត់បន្ថយ (Reduce) ប្រើប្រាស់ឡើងវិញ (Reuse) និងកែច្នៃ (Recycle) ព្រមទាំងការពង្រឹងយន្តការតាមដាន និងត្រួតពិនិត្យការបំពុល ។

បច្ចុប្បន្ន សំរាម សំណល់រឹងទីប្រជុំជននៅកម្ពុជាចំនួនប្រមាណ ២ លានតោន/ឆ្នាំ (ឆ្នាំ២០១៩) ត្រូវបានប្រមូល និងដឹកជញ្ជូនយកទៅទុកដាក់នៅទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅទូទាំងប្រទេស ជាមួយនឹងអត្រាកំណើនប្រមាណជា ១៥ %/ឆ្នាំ ។ តាមការប៉ាន់ស្មាន ប្រសិនបើសំរាម សំណល់រឹងទីប្រជុំជនទាំងអស់ត្រូវបានប្រមូលនោះ បរិមាណសំរាម សំណល់រឹងទីប្រជុំជនសរុបអាចនឹងមានចំនួនរហូតដល់ ៣ លានតោន/ឆ្នាំ ។ និយាយដោយឡែក សំរាម សំណល់រឹងទីប្រជុំជន ដែលនៅសល់ត្រូវបានទុក និងបោះចោល ទៅតាមវិធីផ្សេងៗ និងនិយាយជារួម សំរាម សំណល់រឹងទីប្រជុំជន នៅពុំទាន់ត្រូវបានញែក, វេចខ្ចប់ និងទុកដាក់ ឱ្យបានត្រឹមត្រូវតាមក្រឹត្យក្រម និងស្តង់ដារអនាម័យបរិស្ថាននៅឡើយទេ ។ ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក៏មិនទាន់មានការត្រួតពិនិត្យការបំពុល ឬប្រព័ន្ធការពារ និងមិនទាន់អនុលោមតាមនិយាម ស្តង់ដារនៃប្រទេសជឿនលឿននៅឡើយទេ ។

កង្វះខាតនូវប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព បានបង្កផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំងដល់គុណភាពបរិស្ថាន និងផាសុកភាពរបស់ប្រជាជន ។ ប្រព័ន្ធគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព មិនត្រឹមតែរួមចំណែកដល់ការពង្រឹងគុណភាព និងនិរន្តរភាពសេវាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយសម្រាលបន្ទុកថវិកាជាតិក្នុងការធ្វើឧបត្ថម្ភធន, កាត់បន្ថយ និងសន្សំសំចៃការប្រើប្រាស់ និងការទទួលទាន, ព្រមទាំងរួមចំណែកដល់ការបង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច ជំរុញការលូតលាស់នៃសេដ្ឋកិច្ចវិលជុំ (Circular Economy) និងជួយរួមចំណែកសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ។

បញ្ហាប្រឈមចម្បងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន គឺកំណើនយ៉ាងឆាប់រហ័សទាំងបរិមាណ និងសមាសភាគនៃសំរាម សំណល់រឹងទីប្រជុំជន, កង្វះហេដ្ឋារចនាសម្ព័ន្ធ, ការគ្រប់គ្រង, យន្តការហិរញ្ញប្បទាន, គោលនយោបាយ, ព្រមទាំងការចូលរួមរបស់គ្រប់តួអង្គពាក់ព័ន្ធនៅមានកម្រិត ។ ទោះជាយ៉ាងនេះក្តី បញ្ហាប្រឈមទាំងនេះអាចដោះស្រាយបានតាមរយៈ៖ ការផ្លាស់ប្តូរឥរិយាបថ, ទម្លាប់, របៀបរបបរស់នៅ និងការធ្វើអាជីវកម្ម ផលិតកម្មរបស់អ្នកបង្កើត និងបញ្ចេញសំរាម សំណល់រឹងទីប្រជុំជន ព្រមទាំងការយល់ដឹងរបស់ពួកគាត់ ដោយចាត់ទុកថា "**សំណល់ជាធនធាន**" រឺឯ "**អ្នកបង្កើតសំរាមមានភាតព្វកិច្ចបង់ថ្លៃសេវា**" និងការបង្កើត និងដាក់ឱ្យដំណើរការនូវប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយប្រសិទ្ធភាព ។

ក្នុងបរិការណ៍នេះ ការដាក់ចេញនូវគោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ២០២០-២០៣០ គឺមានភាពចាំបាច់បន្ទាន់ និងមានភាពយូរអង្វែងដែលឆ្លើយតបទៅនឹងតម្រូវការជាសារវន្ត ក្នុងការដោះស្រាយកង្វល់នាពេលបច្ចុប្បន្នលើការចោលសំរាម សំណល់រឹងទីប្រជុំជន មិនបានត្រឹមត្រូវ នៅតាមតំបន់ទីប្រជុំជន, រាជធានី, ក្រុង និងស្រុកដែលបណ្តាលឱ្យមានផលប៉ះពាល់អវិជ្ជមានមកលើសុខភាពប្រជាជន ប្រព័ន្ធអេកូឡូស៊ី និងសោភ័ណភាពទីប្រជុំជន ។ ទន្ទឹមនឹងនេះ ស្របពេលដែលប្រទេសកម្ពុជាស្ថិតនៅក្នុងដំណើរវិវឌ្ឍន៍ពីប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប ឈានទៅប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ គោលនយោបាយនេះនឹងជួយជំរុញឱ្យជីវភាពរស់នៅរបស់ប្រជាជនកាន់តែមានភាពប្រសើរឡើង, ការអភិវឌ្ឍទីក្រុងក៏ត្រូវបានកែលម្អ និងធ្វើទំនើបកម្មជាប្រចាំសំដៅប្រែក្លាយទៅជាទីក្រុងទំនើបប្រកបដោយផាសុកភាព ។

គោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ២០២០-២០៣០ មានចក្ខុវិស័យ *"រួមចំណែកធ្វើឱ្យព្រះរាជាណាចក្រកម្ពុជាកាន់តែមានបរិស្ថានស្អាត ការរស់នៅប្រកបដោយផាសុកភាព, សុខុមាលភាព, និងសោភ័ណភាពទាក់ទាញ សមស្របទៅនឹងកំណើននគរូបនីយកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ចដ៏ឆាប់រហ័ស"* ។ គោលនយោបាយនេះមានគោលបំណង *"រៀបចំបង្កើត និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនមានលក្ខណៈទំនើប, គ្រប់ជ្រុងជ្រោយ ដោយគិតគូរអំពីប្រសិទ្ធភាពសេដ្ឋកិច្ច, លទ្ធភាពធនធានហិរញ្ញវត្ថុ, និរន្តរភាពបរិស្ថាន និងទិដ្ឋភាពសង្គម"* ។

ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងគោលបំណងនៃគោលនយោបាយខាងលើ រាជរដ្ឋាភិបាលបានកំណត់នូវគោលដៅដូចខាងក្រោម៖

១- បង្កើនប្រសិទ្ធភាព និងពង្រីកវិសាលភាពនៃការផ្តល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន តាមវិធីសាស្ត្រចម្រុះ ជាពិសេសគោលការណ៍ ៣អ៊ែ ដោយប្រើប្រាស់បច្ចេកវិទ្យាសមស្រប

២- ពង្រឹងប្រសិទ្ធភាព និងសក្តិសិទ្ធភាពក្នុងការអនុវត្តមុខងាររបស់រដ្ឋបាលរាជធានី, ក្រុង និងស្រុក ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

៣- រៀបចំឱ្យមានយន្តការស្ថាប័ន និងក្របខណ្ឌច្បាប់, បច្ចេកទេស, បច្ចេកវិទ្យា និងហិរញ្ញប្បទាន សម្រាប់គាំទ្រ ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

៤- ដាក់ឱ្យអនុវត្តនូវកញ្ចប់វិធានការលើកទឹកចិត្តរបស់រាជរដ្ឋាភិបាល ដើម្បីជំរុញឱ្យមានការចូលរួមពីវិស័យឯកជនក្នុងកិច្ចការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

៥- លើកកម្ពស់ការអប់រំ, ផ្សព្វផ្សាយ និងជំរុញឱ្យមានការចូលរួមពីសំណាក់សាធារណជនក្នុងការអនុវត្តកាតព្វកិច្ចគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន ។

ក្នុងន័យជំរុញឱ្យសម្រេចបាននូវចក្ខុវិស័យ, គោលបំណង និងគោលដៅដែលបានកំណត់ និងដើម្បីឱ្យគោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននេះ អនុវត្តទៅប្រកបដោយរលូន, មានប្រសិទ្ធភាព, ប្រសិទ្ធផល និងតម្លាភាព រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវចង្កោមវិធានការគោលនយោបាយធំៗចំនួន ៥ ដោយក្នុងនោះ ត្រូវបានលម្អិតចេញជាបណ្តាវិធានការជាក់លាក់ ដែលត្រូវបែងចែកជាវិធានការរយៈពេលខ្លី, មធ្យម និងវែង ។ ចង្កោមវិធានការគោលនយោបាយធំៗទាំង ៥ មានដូចខាងក្រោម៖

១- ការកំណត់ក្របខណ្ឌ, លិខិតបទដ្ឋានគតិយុត្ត, ក្របខណ្ឌការងារ និងការទទួលខុសត្រូវរបស់ក្រសួង, ស្ថាប័ន, អង្គភាព និងបុគ្គលពាក់ព័ន្ធនានាលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

២- ការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលរាជធានី, ក្រុង និងស្រុក

៣- ការកំណត់ជម្រើសបច្ចេកទេស, បច្ចេកវិទ្យា និងហេដ្ឋារចនាសម្ព័ន្ធសមស្រប សម្រាប់កាត់បន្ថយការបង្កើតសំរាម សំណល់រឹងទីប្រជុំជន

៤-ការបង្កើតឱកាសវិនិយោគដល់វិស័យឯកជន លើការផ្តល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

៥- ការលើកកម្ពស់ការអប់រំ, ការផ្សព្វផ្សាយ និងការជំរុញឱ្យមានការចូលរួមពីសាធារណជនអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ។

ដើម្បីសម្រេចបានតាមយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលសម្រេចដាក់ឱ្យអនុវត្តនូវផែនការសកម្មភាពអាទិភាពជាគោលសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រួមមានជាអាទិ៍៖

១- ការរៀបចំយន្តការស្ថាប័ន និងការបង្កើតក្របខណ្ឌគតិយុត្ត ទាំងនៅថ្នាក់ជាតិ (គណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន) និងថ្នាក់ក្រោមជាតិ (រដ្ឋបាលរាជធានី, ក្រុង និងស្រុក) ។

២- ការកសាងសមត្ថភាព និងការបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រខាងលើ ។

ដើម្បីគាំទ្រដំណើរការអនុវត្តគោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ២០២០-២០៣០ នេះ រាជរដ្ឋាភិបាលនឹងរៀបចំបង្កើតយន្តការហិរញ្ញប្បទានពីប្រភពថវិកាអន្តរាគមន៍ពី

ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, អំណោយ និងវិភាគទានពីដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, វិស័យឯកជន និងពីសប្បុរសជននានា, ថវិកាទទួលបានពីអ្នកបង់ថ្លៃសម្រាប់ការប្រើប្រាស់សេវាសម្អាត, ប្រមូល, ដឹកជញ្ជូន, ទុកដាក់សំរាម សំណល់រឹង និងការវិនិយោគ ។

រាជរដ្ឋាភិបាលក៏បានត្រៀមលក្ខណៈក្នុងការឆ្លើយតបទៅនឹងហានិភ័យនានាដែលអាចកើតមានឡើងនៅក្នុងការអនុវត្តវិធានការទាំងនេះ តាមរយៈការកំណត់ទិសដៅសំខាន់ៗ មួយចំនួនដូចខាងក្រោម៖

១- ការពង្រឹងការអនុវត្តច្បាប់, បទដ្ឋានគតិយុត្តិ ពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ។

២-ការផ្តល់ថវិកាអន្តរាគមន៍របស់រាជរដ្ឋាភិបាល ដើម្បីធានានូវនិរន្តរភាពនៃប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន នៅក្នុងដំណាក់កាលមួយចំនួនរបស់វដ្តនៃការគ្រប់គ្រងសំរាម ។

ទន្ទឹមនេះ ក្រសួង-ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាធារណជន និងសហគមន៍មូលដ្ឋាន ត្រូវចូលរួមសហការសម្របសម្រួល និងអនុវត្តតាមវិធានការគោលនយោបាយលម្អិតនីមួយៗ ដែលបានដាក់ចេញនៅក្នុងឯកសារគោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ២០២០-២០៣០ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីឱ្យការអនុវត្តគោលនយោបាយនេះសម្រេចបានជោគជ័យដូចបានរំពឹងទុក និងប្រកបដោយប្រសិទ្ធភាព, ប្រសិទ្ធផល និងតម្លាភាព ។

ទន្ទឹមនេះ ក្រសួង-ស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាល ត្រូវប្រកាន់ខ្ជាប់នូវអភិក្រមការងារប្រកបដោយបុរេសកម្ម និងសកម្ម ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីធានាបាននូវភាពជោគជ័យនៃការអនុវត្តគោលនយោបាយនេះ ។ រាជរដ្ឋាភិបាល នឹងផ្តល់ការលើកទឹកចិត្តដល់ភាគីពាក់ព័ន្ធដែលនឹងរួមចំណែកដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជននេះ ។ ប្រជាជនកម្ពុជាគ្រប់រូប, សហគមន៍មូលដ្ឋាន, ដៃគូអភិវឌ្ឍន៍ និងតួអង្គពាក់ព័ន្ធទាំងអស់ ត្រូវសកម្មចូលរួមអនុវត្តគោលនយោបាយនេះ និងប្រកាន់ខ្ជាប់នូវកាតព្វកិច្ចជាពលរដ្ឋល្អក្នុងការចូលរួមថែរក្សាអភិរក្សបរិស្ថានក្រោមពាក្យស្លោក "**កម្ពុជាស្អាតផ្តើមចេញពីយើងម្នាក់ៗ** "ដែលជាបុរេលក្ខខណ្ឌកំណត់ភាពជោគជ័យ នៃសមរភូមិកែទម្រង់ និងការដ្ឋានការងារថ្មីមួយនេះ ។

# មាតិកា

**១- សេចក្ដីផ្ដើម** ...... ១

១.១- បរិការណ៍ទូទៅ ...... ១

១.២- ការបង្កើតសំរាម សំណល់រឹងនៅកម្ពុជា ...... ១

១.៣- របៀបគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅកម្ពុជាបច្ចុប្បន្ន ...... ២

១.៤- សារសំខាន់នៃប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយនិរន្តរភាព ...... ២

១.៥- ការកំណត់បញ្ហាប្រឈម, កាលានុវត្តភាព និងលក្ខខណ្ឌតម្រូវ ...... ៣

**១.៥.១- បញ្ហាប្រឈម** ...... ៣

**១.៥.២- កាលានុវត្តភាព** ...... ៥

**១.៥.៣- លក្ខខណ្ឌតម្រូវ** ...... ៥

**២- ចក្ខុវិស័យ** ...... ៦

**៣- គោលបំណង** ...... ៦

**៤- គោលដៅ** ...... ៦

**៥- យុទ្ធសាស្ត្រ** ...... ៧

៥.១- ការកំណត់ក្របខណ្ឌលិខិតបទដ្ឋានគតិយុត្ត, ក្របខណ្ឌការងារ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាព និងបុគ្គលពាក់ព័ន្ធនានាលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ...... ៧

**៥.១.១- វិធានការរយៈពេលខ្លី (១-២ ឆ្នាំ)** ...... ៧

**៥.១.២- វិធានការរយៈពេលមធ្យម (៣-៥ ឆ្នាំ)** ...... ៧

**៥.១.៣- វិធានការរយៈពេលវែង(៦-១០ ឆ្នាំ)** ...... ៨

៥.២- ការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលរាជធានី, ក្រុង និងស្រុក ...... ៨

**៥.២.១- វិធានការរយៈពេលខ្លី (១-២ ឆ្នាំ)** ...... ៨

**៥.២.២- វិធានការរយៈពេលមធ្យម (៣-៥ ឆ្នាំ)** ...... ៩

**៥.២.៣- វិធានការរយៈពេលវែង (៦-១០ ឆ្នាំ)** ...... ៩

៥.៣- ការកំណត់ជម្រើសបច្ចេកទេស, បច្ចេកវិទ្យា និងហេដ្ឋារចនាសម្ព័ន្ធសមស្រប សម្រាប់កាត់បន្ថយការបង្កើតសំរាម សំណល់រឹងទីប្រជុំជន ...... ៩

**៥.៣.១- វិធានការរយៈពេលខ្លី (១-២ ឆ្នាំ)** ...... ៩

**៥.៣.២- វិធានការរយៈពេលមធ្យម (៣-៥ ឆ្នាំ)** ...... ១០

**៥.៣.៣- វិធានការរយៈពេលវែង (៦-១០ ឆ្នាំ)** ...... ១០

៥.៤ -ការបង្កើតឱកាសវិនិយោគដល់វិស័យឯកជន លើការផ្ដល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ...... ១០

**៥.៤.១- វិធានការរយៈពេលខ្លី (១-២ ឆ្នាំ)** ...... ១១

**៥.៤.២- វិធានការរយៈពេលមធ្យម (៣-៥ ឆ្នាំ)** ...... ១១

**៥.៤.៣- វិធានការរយៈពេលវែង (៦-១០ ឆ្នាំ)......១១**

៥.៥- ការលើកកម្ពស់, ការអប់រំ, ការផ្សព្វផ្សាយ និងការជំរុញឱ្យមានការចូលរួមពីសាធារណជនអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន......១២

**៥.៥.១- វិធានការរយៈពេលខ្លី (១-២ ឆ្នាំ)......១២**

**៥.៥.២- វិធានការរយៈពេលមធ្យម និងវែង (៣-១០ ឆ្នាំ)......១២**

**៦- ផែនការសកម្មភាព និងដំណើរការអនុវត្តគោលនយោបាយ......១៣**

៦.១- ការរៀបចំយន្តការស្ថាប័ន និងការបង្កើតក្របខណ្ឌគតិយុត្ត......១៣

**៦.១.១- ថ្នាក់ជាតិ......១៣**

**៦.១.២- ថ្នាក់ក្រោមជាតិ......១៤**

៦.២- ការកសាងសមត្ថភាព និងការបណ្តុះបណ្តាលធនធានមនុស្ស......១៤

**៧- យន្តការហិរញ្ញប្បទាន......១៥**

**៨- ការគ្រប់គ្រងហានិភ័យ......១៥**

**៩- ស្ថាប័នទទួលខុសត្រូវលើការអនុវត្តគោលនយោបាយគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងការចូលរួមពីអ្នកពាក់ព័ន្ធនានាផ្សេងទៀត......១៦**

៩.១- រដ្ឋបាលថ្នាក់ជាតិ......១៦

**៩.១.១- គណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន......១៦**

**៩.១.២- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ......១៦**

**៩.១.៣- ក្រសួងមហាផ្ទៃ និង គណៈកម្មាធិការសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)......១៧**

**៩.១.៤- ក្រសួងបរិស្ថាន......១៧**

**៩.១.៥- ក្រសួងទេសចរណ៍ និង គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត (គ.ជ.វ.ទ)......១៧**

**៩.១.៦- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍......១៧**

**៩.១.៧- ក្រសួងរ៉ែ និងថាមពល......១៨**

**៩.១.៨- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា......១៨**

**៩.១.៩- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់......១៨**

**៩.១.១០- ក្រសួងសាធារណការ និងដឹកជញ្ជូន......១៨**

**៩.១.១១- ក្រសួងធនធានទឹក និងឧតុនិយម......១៨**

**៩.១.១២- ក្រសួងព័ត៌មាន......១៩**

**៩.១.១៣- ក្រសួងអប់រំ យុវជន និងកីឡា......១៩**

**៩.១.១៤- អគ្គិសនីកម្ពុជា......១៩**

៩.២- រដ្ឋបាលថ្នាក់ក្រោមជាតិ......១៩

**៩.២.១- រដ្ឋបាលរាជធានី ខេត្ត ....................................................... ១៩**

**៩.២.២- រដ្ឋបាលក្រុង ស្រុក....................................................... ២០**

៩.៣- អង្គការមិនមែនរដ្ឋាភិបាល....................................................... ២០

៩.៤- វិស័យឯកជន....................................................... ២០

៩.៥- ការចូលរួមពីសាធារណជន និងសហគមន៍មូលដ្ឋាន....................................................... ២០

៩.៦- ទំនាក់ទំនងជាមួយសហគមន៍អន្តរជាតិ ....................................................... ២១

**១០- យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ**....................................................... ២១

១០.១- ថ្នាក់ជាតិ ....................................................... ២២

១០.២- ថ្នាក់ក្រោមជាតិ ....................................................... ២២

**១១- សេចក្តីសន្និដ្ឋាន....................................................... ២២**

**សន្ទានុក្រម....................................................... ២៤**

**ឧបសម្ព័ន្ធ ១ ផែនការគោលនយោបាយស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ២០២០ - ២០៣០ ....................................................... ២៥**

## ១- សេចក្តីផ្តើម

### ១.១- បរិការណ៍ទូទៅ

ក្នុងរយៈពេលជាងមួយទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាមានការរីកចម្រើនលើគ្រប់វិស័យ ព្រមទាំងសម្រេចបានកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំជាមធ្យមក្នុងអត្រាលើសពី ៧% ។ ការរីកចម្រើនយ៉ាងលឿននេះ ប្រព្រឹត្តទៅបានដោយសារកត្តាសន្តិភាព និងសុវត្ថិភាពទូទាំងប្រទេសដែលកម្ពុជាសម្រេចបានប្រកបដោយជោគជ័យ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងទស្សនវិស័យវែងឆ្ងាយរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** ។ ទន្ទឹមនឹងការខិតខំប្រឹងប្រែងអភិវឌ្ឍសង្គម-សេដ្ឋកិច្ច រួមទាំងការកាត់បន្ថយភាពក្រីក្រ រាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់ក្នុងការទប់ស្កាត់ការបំពុលបរិស្ថានដែលកើតចេញពីដំណើរការអភិវឌ្ឍផងដែរ ។ សម្រាប់នីតិកាលទី ៦ នៃរដ្ឋសភា រាជរដ្ឋាភិបាលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នៅក្នុង**មុំទី៤**«*ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ*» នៃ**ចតុកោណទី៤**«*ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន*» ដោយផ្តោតអាទិភាពលើការបន្តពង្រឹងការគ្រប់គ្រងសំណល់រឹង, រាវ, ឧស្ម័ន និងសារធាតុគ្រោះថ្នាក់តាមរយៈការអនុវត្តគោលការណ៍ ៣អ៊ែ (3Rs): **កាត់បន្ថយ (Reduce), ប្រើប្រាស់ឡើងវិញ (Reuse) និងកែច្នៃ (Recycle)** ព្រមទាំងការពង្រឹងយន្តការតាមដាន និងត្រួតពិនិត្យការបំពុល ។

ទន្ទឹមនឹងការធ្វើឱ្យកម្រិតជីវភាពរស់នៅរបស់ប្រជាជនកាន់តែប្រសើរឡើង កម្ពុជាក៏នឹងប្រឈមបញ្ហាមួយចំនួនផងដែរ នៅក្នុងដំណើរវិវឌ្ឍន៍ឈានពីប្រទេសដែលមានប្រាក់ចំណូលទាប ទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ ។ ជាក់ស្តែង ទីក្រុងដែលកំពុងត្រូវបានកែលម្អ និងធ្វើទំនើបកម្មដើម្បីប្រែក្លាយទៅជាទីក្រុងទំនើបប្រកបដោយផាសុកភាព ស្របជាមួយនឹងកំណើនតម្រូវការប្រើប្រាស់ឧបករណ៍ និងសម្ភារដែលកាន់តែសំបូរបែប បាននិងកំពុងពន្លឿនកំណើនសំរាម សំណល់រឹងទីប្រជុំជន គួរឱ្យកត់សម្គាល់ និងត្រូវមានការយកចិត្តទុកដាក់ខ្ពស់ ។

### ១.២- ការបង្កើតសំរាម សំណល់រឹងនៅកម្ពុជា

បច្ចុប្បន្ន សំរាម សំណល់រឹងទីប្រជុំជនចំនួនប្រមាណ ២ លានតោន/ឆ្នាំ(ឆ្នាំ២០១៩) ត្រូវបានប្រមូល និងដឹកជញ្ជូនយកទៅទុកដាក់នៅទីលាននៅទូទាំងប្រទេស ជាមួយនឹងអត្រាកំណើនប្រមាណជា ១៥%/ឆ្នាំ ។ តាមការប៉ាន់ស្មាន ប្រសិនបើសំរាម សំណល់រឹងទីប្រជុំជនទាំងអស់ត្រូវបានប្រមូលទាំងអស់ នោះបរិមាណសំរាម សំណល់រឹងទីប្រជុំជនសរុបអាចនឹងកើនដល់ ៣ លានតោន/ឆ្នាំ ។ ការផ្តល់សេវាប្រមូល និងដឹកជញ្ជូនដែលកំពុងដំណើរការ អនុវត្តបានត្រឹមប្រមាណជា ៦០% ប៉ុណ្ណោះ នៃបរិមាណសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតសរុប ។ ដោយឡែកសំរាម សំណល់រឹងទីប្រជុំជន ដែលនៅសល់ត្រូវបានទុក និងបោះចោលទៅតាមវិធីផ្សេងៗ ។ នាពេលបច្ចុប្បន្ន, ការបង្កើតសំរាម សំណល់រឹងទីប្រជុំជន ជាមធ្យមក្នុងមនុស្សម្នាក់មានប្រហែល ០,៨០ គ.ក្រ/ថ្ងៃ សម្រាប់រាជធានី, ក្រុង និងស្រុក ដែលមានការអភិវឌ្ឍខ្លាំង ។ សម្រាប់ទីប្រជុំជន, ក្រុង, និងស្រុក ដែលមានការអភិវឌ្ឍមធ្យម មានប្រមាណ ០,៥០-០,៨០ គ.ក្រ/ថ្ងៃ និងសម្រាប់

ទីប្រជុំជនផ្សេងទៀត ០,៣០-០,៥០ គ.ក្រ/ថ្ងៃ អាស្រ័យទៅតាមស្ថានភាពសេដ្ឋកិច្ច និងភូមិសាស្ត្រនៃតំបន់នីមួយៗ ។

## ១.៣- របៀបគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន នៅកម្ពុជាបច្ចុប្បន្ន

បច្ចុប្បន្ន សំរាម សំណល់រឹងទីប្រជុំជន ដែលត្រូវបានបញ្ចេញពីគេហដ្ឋាន, មជ្ឈមណ្ឌលពាណិជ្ជកម្ម, រោងចក្រ, សហគ្រាស, សិប្បកម្ម និងមន្ទីរពេទ្យ ។ល។ ពុំទាន់ត្រូវបានញែក, វេចខ្ចប់ និងទុកដាក់ឱ្យបានត្រឹមត្រូវតាមក្រឹត្យក្រម និងស្តង់ដារអនាម័យបរិស្ថាន ដែលជាហេតុបង្កផលប៉ះពាល់ដល់សុខភាពសាធារណៈ, បរិស្ថាន និងសោភ័ណភាពរបស់ទីប្រជុំជនទាំងមូល ។ ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ដែលកំពុងមានសកម្មភាពនៅតាមរាជធានី, ក្រុង និងស្រុក ត្រូវបានរៀបចំយ៉ាងសាមញ្ញបំផុត ដោយមិនទាន់មានការត្រួតពិនិត្យការបំពុល ឬ ប្រព័ន្ធការពារឡើយ និងពុំទាន់អនុលោមតាមនិយាម ស្តង់ដារនៃប្រទេសជឿនលឿននៅឡើយ ។ម្យ៉ាងវិញទៀត ធនធានដែលអាចយកមកប្រើប្រាស់ និងកែច្នៃ មិនទាន់ត្រូវបានទាញប្រមូលយកឱ្យអស់សក្តានុពល ហើយផ្ទុយទៅវិញបានដាក់សម្ពាធកាន់តែធ្ងន់ក្នុងការចំណាយយកទៅចោលនៅទីលាន ។ ប្រការទាំងនេះ តម្រូវឱ្យយើងទាំងអស់គ្នាជាប្រទេស និងសង្គមជាតិទាំងមូលត្រូវធ្វើការកែលម្អជាបន្ទាន់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវគុណភាពបរិស្ថាន, លើកកម្ពស់សោភ័ណភាពទីប្រជុំជន និងឈានទៅសម្រេចឱ្យបាននូវគោលការណ៍សេដ្ឋកិច្ចបៃតងក្នុងបរិបទនៃគោលដៅការអភិវឌ្ឍប្រកបដោយនិរន្តរភាព ។

## ១.៤- សារសំខាន់នៃប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយនិរន្តរភាព

ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន នៅតែជាបញ្ហាប្រឈមដ៏ធំនៅក្នុងតំបន់ទីក្រុងនៅទូទាំងពិភពលោក ជាពិសេសនៅក្នុងរាជធានី, ក្រុង និងស្រុក ដែលកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស ។ កង្វះខាតនូវប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព បានបង្កផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំងដល់គុណភាពបរិស្ថាន ហើយក៏ជាកត្តាកំណត់ដោយផ្ទាល់ទៅលើឥរិយាបថ, ទម្លាប់, របៀបរបបរស់នៅ និងការធ្វើអាជីវកម្មផលិតកម្មរបស់អ្នកបង្កើត និងបញ្ចេញសំរាម សំណល់រឹងទីប្រជុំជន ។ ប្រព័ន្ធគ្រប់គ្រងដែលមានសក្តិសិទ្ធភាព មិនត្រឹមតែរួមចំណែកដល់ការពង្រឹងគុណភាព និងនិរន្តរភាពសេវាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយសម្រាលបន្ទុកថវិកាជាតិក្នុងការធ្វើឧបត្ថម្ភធន, កាត់បន្ថយ និងសន្សំសំចៃការប្រើប្រាស់ និងការទទួលទាន រួមចំណែកដល់ការបង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច ជំរុញការលូតលាស់នៃសេដ្ឋកិច្ចវិលជុំ (Circular Economy) និងជួយរួមចំណែកសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ។

ជាទូទៅ វដ្តនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រួមមាន៖ ការបង្កើត, ការស្តុក, ការប្រមូល, ការផ្ទេរ និងការដឹកជញ្ជូន, ការកែច្នៃ និងការទុកដាក់ចុងក្រោយ ។ ប្រព័ន្ធគ្រប់គ្រងថ្មីនឹងគិតគូរខ្ពស់ដល់កិច្ចគាំពារបរិស្ថាន, ការការពារសុខភាពសាធារណៈ និងជម្រើសនៃការប្រើបច្ចេកវិទ្យាដែលមានថ្លៃចំណាយសមរម្យ និងអាចឆ្លើយតបទៅនឹងការរីកចម្រើននៃសេដ្ឋកិច្ចជាតិ ។ ខណៈដែលការអភិវឌ្ឍទីក្រុង និងទីប្រជុំជនកំពុងមានសន្ទុះលឿន រាជរដ្ឋាភិបាលមានភាពចាំបាច់ក្នុងការដាក់ចេញជាបន្ទាន់នូវការកែទម្រង់

លើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយប្រសិទ្ធភាពបរិស្ថាន ដោយក្នុងនោះត្រូវជំរុញការអនុវត្តគោលការណ៍ ៣អ៊ែ ដែលជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងកិច្ចគាំពារបរិស្ថាន និងអភិរក្សធនធាន ។

### ១.៥- ការកំណត់បញ្ហាប្រឈម, កាលានុវត្តភាព និងលក្ខខណ្ឌតម្រូវ

បញ្ហាប្រឈមចម្បងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន គឺកំណើនយ៉ាងឆាប់រហ័សទាំងបរិមាណ និងសមាសភាគផ្សំ, កង្វះហេដ្ឋារចនាសម្ព័ន្ធ, ការគ្រប់គ្រង, ហិរញ្ញប្បទាន, គោលនយោបាយព្រមទាំងការចូលរួមនៅមានកម្រិតរបស់គ្រប់តួអង្គពាក់ព័ន្ធ ។ ទោះជាយ៉ាងនេះ បញ្ហាប្រឈមទាំងនេះអាចត្រូវបានដោះស្រាយ តាមរយៈការផ្លាស់ប្តូរឥរិយាបថ និងការយល់ដឹងរបស់អ្នកបង្កើតសំរាម សំណល់រឹងទីប្រជុំជន ដោយចាត់ទុកថា "**សំណល់ជាធនធាន**" ។ ជាមួយគ្នានេះ ការប្រើប្រាស់បច្ចេកវិទ្យាសមស្រប ក៏អាចបំប្លែងសំរាម សំណល់រឹងទីប្រជុំជន ទៅជាថាមពលផងដែរ ។ លើសពីនេះ ការញែកតាំងតែពីដើមប្រភព, ការកែច្នៃ និងការទាញយកធនធានមកប្រើប្រាស់ឡើងវិញក្នុងអត្រាមួយខ្ពស់ នឹងជួយកាត់បន្ថយចំណាយសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងការសាយភាយឧស្ម័នមេតាន និងកាបូនឌីអុកស៊ីតជាដើម ដែលធ្វើឱ្យមានការប្រែប្រួលអាកាសធាតុ ។ ខណៈដែលសង្គមជាតិទាំងមូលកាន់តែមានឆន្ទៈចូលរួមចំណែកការពារ និងអភិរក្សបរិស្ថាន, រាជរដ្ឋាភិបាលប្តេជ្ញាអនុវត្តនូវប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន តាមវិធានការចម្រុះ ដែលមិនត្រឹមតែអាចជួយសន្សំសំចៃដល់ការចំណាយលើការគ្រប់គ្រង និងបង្កើតឱ្យមានអន្តរសកម្មរវាងបណ្តាវិស័យផ្សេងទៀត សំដៅធានានូវនិរន្តរភាពនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងបរិស្ថានប៉ុណ្ណោះទេ ប៉ុន្តែក៏ជាមូលដ្ឋានគ្រឹះមួយក្នុងការកសាងប្រជាជាតិយើង ឆ្ពោះទៅជាអរិយប្រទេសនាពេលអនាគត ។

#### ១.៥.១- បញ្ហាប្រឈម

ការអនុវត្តជាក់ស្តែងលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅជួបប្រទះឧបសគ្គ រួមមានជាអាទិ៍៖

- **កង្វះច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត៖** ដ្បិតរាជរដ្ឋាភិបាលបានដាក់ចេញជាបន្តបន្ទាប់នូវបទប្បញ្ញត្តិមួយចំនួនសំដៅគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន, ក្របខណ្ឌច្បាប់, លិខិតបទដ្ឋានគតិយុត្តដែលគ្រប់ជ្រុងជ្រោយ, យន្តការគ្រប់គ្រង ក៏ដូចជាផែនការសកម្មភាព និងប្រតិបត្តិការនៅមិនទាន់ត្រូវបានរៀបចំឱ្យបានសមស្របនៅឡើយ ។ ខណៈដែលការផ្តល់សេវានៅមានកម្រិត ការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត បានជួបប្រទះនូវបញ្ហាប្រឈមជាច្រើន ដែលពុំទាន់អាចរកដំណោះស្រាយបាន ។ ជាមួយគ្នានេះ ប្រព័ន្ធទិន្នន័យ និងព័ត៌មាន ដែលមានភាពប្រទាក់ក្រឡាអំពីប្រភព, ប្រភេទ និងបរិមាណនៃការបង្កើតសំរាម សំណល់រឹងទីប្រជុំជនក៏នៅមានភាពខ្វះខាតផងដែរ ។ រដ្ឋបាលថ្នាក់ក្រោមជាតិ នៅមិនទាន់បានរៀបចំច្បាប់ទម្លាប់ និងផែនការសកម្មភាពការងារឱ្យបានជាក់លាក់ ជាពិសេសការរៀបចំឱ្យមានប្រព័ន្ធច្បាស់លាស់សម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។
- **យន្តការស្ថាប័ន៖** ការរៀបចំយន្តការ និងសមត្ថភាពរបស់ស្ថាប័នដែលពុំទាន់មានប្រសិទ្ធភាពបានបង្កឱ្យមានភាពមិនទាន់ច្បាស់លាស់ក្នុងការទទួលយកនូវមុខងារ, តួនាទី, ភារកិច្ច និងការទទួលខុសត្រូវរបស់ស្ថាប័ន, អង្គភាពជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ទាំងកម្រិតគោលនយោបាយ និងប្រតិបត្តិការ ។

ចំពោះមុខ យន្តការស្ថាប័ន គឺជាចំណោទដ៏ធំជាងគេ ដែលត្រូវផ្តោតការយកចិត្តទុកដាក់ និងមានចំណាត់ការជាបន្ទាន់ ព្រមទាំងទាមទារនូវពេលវេលាផងដែរក្នុងការកសាងឱ្យមាននិរន្តរភាព ។

- **យន្តការហិរញ្ញប្បទាន៖** វដ្តនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន នៅពុំទាន់បានឆ្លុះបញ្ចាំងគ្រប់ជ្រុងជ្រោយពីទិដ្ឋភាពសេដ្ឋកិច្ច ដោយរាប់ចាប់តាំងពីការបង្កើតសំរាម សំណល់រឹងទីប្រជុំជន, ការញែក, ការប្រមូល, ការផ្ទេរ, ការធ្វើប្រព្រឹត្តិកម្ម, ការទាញយកធនធាន និងការទុកដាក់ចុងក្រោយ ជាពិសេសអនុលោមតាមគោលការណ៍ **អ្នកបង្កើតសំរាម ត្រូវមានកាតព្វកិច្ចបង់ថ្លៃសេវា** ។ ជាច្រើនឆ្នាំមកហើយ ការបង់ថ្លៃសេវាក្នុងអត្រាទាប មិនសមស្របនឹងបរិមាណសំរាម សំណល់រឹងទីប្រជុំជន ដែលបានបង្កើត, ការវិនិយោគសាធារណៈ និងឧបត្ថម្ភធន ដែលពុំទាន់ឆ្លើយតបនឹងតម្រូវការសម្រាប់ការគ្រប់គ្រងប្រកបដោយគុណភាព និងចីរភាពបរិស្ថាន ក៏ជាដើមហេតុធ្វើឱ្យការគ្រប់គ្រង និងការផ្តល់សេវាជួបបញ្ហានៃការធ្លាក់ចុះផ្នែកគុណភាព និងលែងមាននិរន្តរភាព ។ កិច្ចសហការរវាងរដ្ឋ និងឯកជនដើម្បីជំរុញ និងលើកទឹកចិត្តក្នុងការរួមចំណែកដោះស្រាយបញ្ហា ក៏ដូចជាគោលការណ៍ផលិតករត្រូវមានកាតព្វកិច្ចទទួលខុសត្រូវលើសំណល់ពីការប្រើប្រាស់ផលិតផលរបស់ខ្លួន ត្រូវយកមកអនុវត្តដើម្បីជួយសម្រាលអំរែកបន្ទុកហិរញ្ញវត្ថុ និងធានានូវចីរភាព ។

- **ហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកវិទ្យា៖** កង្វះហេដ្ឋារចនាសម្ព័ន្ធ ដូចជាស្ថានីយផ្ទេរ, ទីលានទុកដាក់, កង្វះការទទួលខុសត្រូវច្បាស់លាស់ក្នុងប្រតិបត្តិការផ្តល់សេវា និងកង្វះការញែកទៅតាមប្រភេទ ព្រមទាំងមធ្យោបាយប្រមូល និងដឹកជញ្ជូនសំរាមមិនទាន់សមស្រប នៅតែជាបញ្ហាប្រឈមក្នុងការធានាការគ្រប់គ្រងប្រកបដោយគុណភាព និងនិរន្តរភាពបរិស្ថាន ។ ជាទូទៅ សំរាម សំណល់រឹងទីប្រជុំជនទាំងអស់ត្រូវបានយកទៅចាក់ចោលនៅទីលានចំហ ដោយពុំទាន់មានការកំណត់ជម្រើសបច្ចេកវិទ្យាក្នុងការគ្រប់គ្រងឱ្យបានច្បាស់លាស់នៅឡើយ ។ ការកែច្នៃសំរាម សំណល់រឹងទីប្រជុំជនភាគច្រើននៅមានលក្ខណៈជាសិប្បកម្មតូចៗ មិនផ្លូវការ ហើយក៏ពុំទាន់ប្រើប្រាស់បច្ចេកវិទ្យាឱ្យបានអស់សក្តានុពលដែរ ។

- **ការផ្សព្វផ្សាយអំពីវិធានការកាត់បន្ថយបរិមាណសំរាម សំណល់រឹងទីប្រជុំជន នៅមានកម្រិត៖** គោលការណ៍ ៣អ៊ែ ដែលត្រូវបានយកមកអនុវត្តជាសកល សំដៅកាត់បន្ថយបរិមាណសំរាម សំណល់រឹងទីប្រជុំជនដែលត្រូវទុកដាក់ចុងក្រោយនៅទីលាន ពុំទាន់ត្រូវបានផ្សព្វផ្សាយទូលំទូលាយទៅដល់គ្រប់មជ្ឈដ្ឋាន និងសាធារណជននៅឡើយ ឯការអនុវត្តទៀតសោត ក៏នៅមានកម្រិតផងដែរ ។

- **ការចូលរួមនៅមានកម្រិតពីសំណាក់សាធារណជន៖** សាធារណជននៅមិនទាន់មានភាពជឿជាក់លើយន្តការនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេស លើប្រសិទ្ធភាពនៃការផ្តល់សេវាសម្អាត, ប្រមូល, ដឹកជញ្ជូន និងគ្រប់គ្រងទីលាន ។ ការអប់រំ និងការផ្សព្វផ្សាយនៅមិនទាន់ទូលំទូលាយ ដែលជាហេតុធ្វើឱ្យការចូលរួមរបស់ប្រជាពលរដ្ឋ ក៏ដូចជាសហគមន៍នៅមានកម្រិត ។ ម្យ៉ាងវិញទៀត ប្រជាជនមួយចំនួននៅពុំទាន់បោះបង់នូវទម្លាប់ចាស់ ដែលបោះចោលសំរាម សំណល់រឹងទីប្រជុំជនពាសវាលពាសកាល ដោយមិនខ្វល់អំពីការវេចខ្ចប់ និងទុកដាក់ក្នុងថង់សំរាមឱ្យបានត្រឹមត្រូវ ហើយខ្លះទៀតថែមនៅមានទម្លាប់ដុតចោលសំរាមនៅទីចំហ ដែលបង្កឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់គុណភាពខ្យល់ និងសុខភាពសាធារណៈទៀតផង ។

### ១.៥. ២- កាលានុវត្តភាព

ថ្វីត្បិតតែការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន កំពុងជួបប្រទះបញ្ហាប្រឈមជាច្រើន ប៉ុន្តែចលនាគាំពារបរិស្ថានជាសកល និងសកម្មភាពមេត្រីភាពបរិស្ថាន ដែលមានការកើនឡើងគួរឱ្យកត់សម្គាល់ បានផ្តល់លក្ខខណ្ឌអំណោយផល ដល់ការកែលម្អ និងការធ្វើឱ្យប្រសើរឡើងវិញលើការគ្រប់គ្រង ។ ជាមួយគ្នានេះ កាលានុវត្តភាពជាច្រើន កំពុងបើកនូវទំព័រសករាជថ្មីក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រួមមានជាអាទិ៍៖

- ឆន្ទៈនយោបាយ និងការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ឯកសារគតិយុត្តមូលដ្ឋាន និងចាំបាច់មួយចំនួនត្រូវបានអនុម័ត និងដាក់ឱ្យប្រើប្រាស់ជាបន្តបន្ទាប់ ជាពិសេសអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដែលមានគោលដៅចម្បងក្នុងការប្រគល់មុខងារ, តួនាទី និងភារកិច្ចនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ជូនទៅរដ្ឋបាលរាជធានី, ក្រុង, និងស្រុក និងការធ្វើប្រតិភូកម្មមុខងារទៅរដ្ឋបាលខណ្ឌ
- កំណើនសេដ្ឋកិច្ច និងប្រាក់ចំណូលមានការកើនឡើង បានផ្លាស់ប្តូរជីវភាព និងរបៀបរបបរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសការផ្តោតការយកចិត្តទុកដាក់ទៅលើអនាម័យ និងបរិស្ថានស្អាតនៅក្នុងជីវភាពប្រចាំថ្ងៃ
- ការផ្លាស់ប្តូរឥរិយាបថប្រជាជនក្នុងការទទួលយក, ប្រើប្រាស់ និងចូលរួមបង់ថ្លៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ផ្នត់គំនិតរបស់យុវជនជំនាន់ថ្មី មានការយកចិត្តទុកដាក់ទៅលើកិច្ចគាំពារបរិស្ថាន ជាពិសេសក្នុងការចូលរួមការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ការចូលរួម និងការគាំទ្រពីដៃគូអភិវឌ្ឍន៍ ព្រមទាំងវិស័យឯកជននៅក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ជាពិសេសការវិនិយោគនៅក្នុងការផ្តល់សេវាសម្អាត, ប្រមូល, ដឹកជញ្ជូន, ការកែច្នៃ និងការទាញយកធនធានពីសំរាម សំណល់រឹងទីប្រជុំជន
- ភាពងាយស្រួល និងឱកាសក្នុងការបញ្ជ្រាបការអប់រំ និងផ្សព្វផ្សាយដល់វិស័យឯកជនអំពីគោលការណ៍ ៣អ៊ែ ខណៈដែលពួកគេបាន និងកំពុងអនុវត្តការប្រមូល, ការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន មានជាអាទិ៍៖ ដប, ជ័រប្លាស្ទិក, ក្រដាស, អាលុយមីញ៉ូម, អាគុយចាស់ៗ, សំណល់គ្រឿងបរិក្ខារអគ្គិសនី និងអេឡិចត្រូនិច, កំទេចក្រណាត់ និងការធ្វើជីកំប៉ុស្តិ៍សរីរាង្គ ។ ជាងនេះទៅទៀត វិធានការលើកទឹកចិត្តពីរាជរដ្ឋាភិបាល ក៏កាន់តែជំរុញបន្ថែមដល់ការចូលរួមក្នុងកិច្ចការនេះ ។

### ១.៥.៣- លក្ខខណ្ឌតម្រូវ

ផ្អែកលើបញ្ហាប្រឈម និងកាលានុវត្តភាពដែលបានរៀបរាប់ខាងលើ រាជរដ្ឋាភិបាលបានគិតគូរអំពីលក្ខខណ្ឌតម្រូវជាអាទិភាព ដើម្បីធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ជាពិសេសការរៀបចំផែនការសកម្មភាពដើម្បីអនុវត្តគោលការណ៍ ៣អ៊ែ ដែលអាចជួយកាត់បន្ថយបរិមាណសំរាម សំណល់រឹងទីប្រជុំជនបានយ៉ាងច្រើន ។ គោលការណ៍ ៣អ៊ែ នឹងត្រូវបានបញ្ជ្រាប និងដាក់ឱ្យអនុវត្ត៖

(i) ក្នុងដំណាក់កាលផលិតកម្ម (ការប្រើប្រាស់វត្ថុធាតុដើម និងដំណើរការផលិត); (ii) ក្នុងដំណាក់កាលចែកចាយ និងប្រើប្រាស់ផលិតផល និង (iii) ក្នុងដំណាក់កាលទុកដាក់សំណល់ចុងក្រោយ; សំដៅកាត់បន្ថយបរិមាណសំរាម សំណល់រឹងទីប្រជុំជនដ៏ច្រើន ដែលបណ្តាលឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ បរិស្ថាន និងសេដ្ឋកិច្ចជាតិ ។

ការដាក់ចេញនូវគោលនយោបាយនេះ គឺមានភាពចាំបាច់បន្ទាន់ និងមានភាពយូរអង្វែង ដែលឆ្លើយតបទៅនឹងតម្រូវការជាសារវន្ត ក្នុងការដោះស្រាយកង្វល់នាពេលបច្ចុប្បន្នលើការចោលសំរាម សំណល់រឹងទីប្រជុំជន មិនបានត្រឹមត្រូវនៅតាមតំបន់ទីប្រជុំជនរាជធានី, ក្រុង និងស្រុក ដែលបណ្តាលឱ្យមានផលប៉ះពាល់អវិជ្ជមានមកលើសុខភាពប្រជាជន, ប្រព័ន្ធអេកូឡូស៊ី និងសោភ័ណភាពទីប្រជុំជន ។ ទន្ទឹមនឹងនេះ ស្របពេលដែលប្រទេសកម្ពុជាស្ថិតនៅក្នុងដំណើរវិវឌ្ឍន៍ពីប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប ឈានទៅប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ គោលនយោបាយនេះនឹងជួយជំរុញធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាជនមានភាពកាន់តែប្រសើរឡើង ការអភិវឌ្ឍទីក្រុងក៏ត្រូវបានកែលម្អ និងធ្វើទំនើបកម្មជាប្រចាំសំដៅប្រែក្លាយទៅជាទីក្រុងទំនើបប្រកបដោយផាសុកភាព ។

## ២ -ចក្ខុវិស័យ

គោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ២០២០-២០៣០ មានចក្ខុវិស័យរួមចំណែកធ្វើឱ្យព្រះរាជាណាចក្រកម្ពុជា កាន់តែមានបរិស្ថានស្អាត, ការរស់នៅប្រកបដោយផាសុកភាព, សុខុមាលភាព និងសោភ័ណភាពទាក់ទាញ សមស្របទៅនឹងកំណើននគរូបនីយកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ចដ៏ឆាប់រហ័ស ។

## ៣- គោលបំណង

គោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ២០២០-២០៣០ មានគោលបំណង រៀបចំបង្កើត និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនមានលក្ខណៈទំនើប និងគ្រប់ជ្រុងជ្រោយ ដោយគិតគូរអំពីប្រសិទ្ធភាពសេដ្ឋកិច្ច, លទ្ធភាពធនធានហិរញ្ញវត្ថុ, និរន្តរភាពបរិស្ថាន និងទិដ្ឋភាពសង្គម ។

## ៤- គោលដៅ

ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងគោលបំណងនៃគោលនយោបាយខាងលើ រាជរដ្ឋាភិបាលបានកំណត់នូវគោលដៅដូចខាងក្រោម៖

១. បង្កើនប្រសិទ្ធភាព និងពង្រីកវិសាលភាពនៃការផ្តល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមវិធីសាស្ត្រចម្រុះ ជាពិសេសគោលការណ៍ ៣អ៊ែ ដោយប្រើប្រាស់បច្ចេកវិទ្យាសមស្រប

២. ពង្រឹងប្រសិទ្ធភាព និងសក្តិសិទ្ធិភាពក្នុងការអនុវត្តមុខងាររបស់រដ្ឋបាលរាជធានី, ក្រុង និងស្រុក ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

៣. រៀបចំឱ្យមានយន្តការស្ថាប័ន និងក្របខណ្ឌច្បាប់, បច្ចេកទេស, បច្ចេកវិទ្យា និងហិរញ្ញប្បទាន សម្រាប់គាំទ្រការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

៤. ដាក់ឱ្យអនុវត្តនូវកញ្ចប់វិធានការលើកទឹកចិត្តរបស់រាជរដ្ឋាភិបាល ដើម្បីជំរុញឱ្យមានការចូលរួមពីវិស័យឯកជនក្នុងកិច្ចការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
៥. លើកកម្ពស់ការអប់រំ, ការផ្សព្វផ្សាយ និងជំរុញឱ្យមានការចូលរួមពីសំណាក់សាធារណជនក្នុងការអនុវត្តកាតព្វកិច្ចគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន ។

## ៥-យុទ្ធសាស្ត្រ

ដើម្បីសម្រេចនូវចក្ខុវិស័យ, គោលបំណង និងគោលដៅដែលបានកំណត់ខាងលើ និងដើម្បីឱ្យគោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ២០២០-២០៣០ នេះ អនុវត្តទៅប្រកបដោយរលូន និងមានប្រសិទ្ធភាព រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការដូចខាងក្រោម៖

### ៥.១- ការកំណត់ក្របខណ្ឌលិខិតបទដ្ឋានគតិយុត្ត, ក្របខណ្ឌការងារ និងការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ន, អង្គភាព និងបុគ្គលពាក់ព័ន្ធនានាលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

យុទ្ធសាស្ត្រនេះនឹងត្រូវបានអនុវត្តតាមរយៈវិធានការគោលនយោបាយដូចខាងក្រោម៖

#### ៥.១.១- វិធានការរយៈពេលខ្លី (១-២ ឆ្នាំ)

- រៀបចំគោលការណ៍ណែនាំអំពីការរៀបចំផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំ សម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- រៀបចំគោលការណ៍ដើម្បីកំណត់ថ្លៃសេវាដែលធានាបាននូវនិរន្តរភាពសេវា ស្របតាមគោលការណ៍សមធម៌នៃការប្រើប្រាស់សេវា និងទិដ្ឋភាពសង្គម
- រៀបចំ និងដាក់ឱ្យប្រើប្រាស់នូវគំរូម៉ូដែលគ្រប់គ្រង, នីតិវិធី និងឯកសារដេញថ្លៃសម្រាប់កិច្ចសន្យាផ្តល់សេវាផ្អែកតាមសមិទ្ធកម្ម ដើម្បីជំរុញការចូលរួមពីវិស័យឯកជន
- កំណត់គោលការណ៍ និងវិធានការកាត់បន្ថយ និងលុបបំបាត់ការបោះចោលសំរាម សំណល់រឹងទីប្រជុំជនបែបអាណាធិបតេយ្យ នៅតាមទីសាធារណៈ និងទីតាំងឯកជន
- ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តថ្នាក់ក្រោមជាតិ សម្រាប់អនុវត្តវិធានការច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន ។

#### ៥.១.២- វិធានការរយៈពេលមធ្យម (៣-៥ ឆ្នាំ)

- រៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីជំរុញការកាត់បន្ថយការបង្កើតសំរាម សំណល់រឹងទីប្រជុំជនជាពិសេសសម្ភារប្លាស្ទិកដែលប្រើបានតែមួយលើក និងប្រែក្លាយសំរាម សំណល់រឹងទីប្រជុំជនទាំងនោះឱ្យមានតម្លៃសេដ្ឋកិច្ច
- រៀបចំលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេស ពាក់ព័ន្ធនឹងការរៀបចំ និងប្រតិបត្តិការទីលានទុកដាក់សំណល់ប្រកបដោយអនាម័យ, អាជ្ញាបណ្ណប្រតិបត្តិការទីលាន, ការប្រមូលសំណាកគំរូ និងការធ្វើវិភាគសមាសភាគសំរាម សំណល់រឹងទីប្រជុំជន ព្រមទាំងប្រព័ន្ធរាយការណ៍ និងការគ្រប់គ្រងទិន្នន័យ

- រៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មាន ទិន្នន័យដែលអាចជឿទុកចិត្តបានអំពីបរិមាណ និងប្រភេទសំរាម សំណល់រឹងទីប្រជុំជន សម្រាប់ការធ្វើសេចក្ដីសម្រេចចិត្ត ក្នុងការរៀបចំយន្តការបង្កើតការផ្ដល់សេវាសម្អាត, ប្រមូល, ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន
- រៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្ដីពីការអនុវត្តគោលការណ៍ ៣អ៊ែ៖ ការកាត់បន្ថយ, ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ ។

### ៥.១.៣- វិធានការរយៈពេលវែង (៦-១០ ឆ្នាំ)

- រៀបចំលិខិតបទដ្ឋាន, គោលការណ៍ណែនាំបច្ចេកទេស និងយន្តការនានាដែលនៅមានខ្វះចន្លោះ ដើម្បីអនុវត្តគោលនយោបាយនេះ ឱ្យកាន់តែមានប្រសិទ្ធភាព
- រៀបចំលិខិតបទដ្ឋានគតិយុត្តិទាំងកម្រិតជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីជំរុញការអនុវត្តវិធានការកាត់បន្ថយការប្រើប្រាស់សម្ភារប្លាស្ទិក និងបង្កើនការប្រើប្រាស់ផលិតផល ផ្សេងជំនួស
- ពិនិត្យ និងរៀបចំកែសម្រួលកម្រៃសេវាសម្អាត, ប្រមូល, ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ដោយគិតគូរពីបរិមាណដែលបានបង្កើត ។

## ៥.២- ការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលរាជធានី, ក្រុង និងស្រុក

យុទ្ធសាស្ត្រនេះនឹងត្រូវបានអនុវត្តតាមរយៈវិធានការគោលនយោបាយដូចខាងក្រោម៖

### ៥.២.១- វិធានការរយៈពេលខ្លី (១-២ ឆ្នាំ)

- រៀបចំអង្គភាព ឬការិយាល័យចំណុះរដ្ឋបាលរាជធានី, ក្រុង និងស្រុក ដើម្បីទទួលខុសត្រូវអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ពង្រឹងភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់រដ្ឋបាលរាជធានី, ក្រុង និងស្រុក ក្នុងការអនុវត្តឱ្យបានពេញលេញនូវមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលបានផ្ទេរពីថ្នាក់ជាតិ
- ពង្រឹងភាពជាម្ចាស់របស់រដ្ឋបាលរាជធានី, ក្រុង និងស្រុក ក្នុងការប្រមូលចំណូល និងការទូទាត់ថ្លៃសេវា ដើម្បីពង្រឹងប្រសិទ្ធភាព និងពង្រីកវិសាលភាពនៃការផ្ដល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- រៀបចំផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំ សម្រាប់ប្រតិបត្តិការសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- រៀបចំយន្តការផ្ដល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន នៅក្នុងដែនសមត្ថកិច្ចគ្រប់គ្រង
- រៀបចំ និងអនុវត្តកម្មវិធីញែកសំរាម សំណល់រឹងទីប្រជុំជន ចាប់ពីដើមខ្សែដល់ចុងខ្សែ ជាមួយនឹងការដឹកជញ្ជូនដាច់ដោយឡែកពីគ្នា
- អនុវត្តវិធានការកាត់បន្ថយ និងលុបបំបាត់ការបោះចោលសំរាម សំណល់រឹងទីប្រជុំជន ស្របអាណាធិបតេយ្យ នៅតាមទីសាធារណៈ និងទីតាំងឯកជន ។

### ៥.២.២- វិធានការរយៈពេលមធ្យម (៣-៥ ឆ្នាំ)

- ពង្រឹង និងពង្រីកសមត្ថភាព ប្រតិបត្តិការសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ឱ្យបាន ទូលំទូលាយ ដោយរៀបចំឱ្យមានធុងសំរាមទៅតាមប្រភេទសំណល់ នៅតាមបណ្តាទីតាំង សមស្រប និងចាំបាច់
- ពង្រីកវិសាលភាពការប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន ដោយវិភាជថវិកាឱ្យដល់ រដ្ឋបាលមូលដ្ឋានគោលដៅ
- បន្ត និងពង្រីកវិសាលភាពការអនុវត្តកម្មវិធីញែកសំរាម សំណល់រឹងទីប្រជុំជន ចាប់ពីដើមខ្សែ ដល់ចុងខ្សែ ជាមួយនឹងការដឹកជញ្ជូនដាច់ដោយឡែកពីគ្នា
- រៀបចំឱ្យមានទីលានទុកដាក់សំណល់ប្រកបដោយអនាម័យ ដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ទៅ តាមលទ្ធភាពជាក់ស្តែង
- បំពាក់ឡដុតសំរាម សំណល់រឹងទីប្រជុំជនខ្នាតតូចដែលមានបច្ចេកទេសត្រឹមត្រូវ និងមិនបង្កផល ប៉ះពាល់ដល់បរិស្ថាន សម្រាប់ទីប្រជុំជនដែលមានបរិមាណសំរាម សំណល់រឹងទីប្រជុំជនតិចតួច
- ជំរុញការអនុវត្តវិធានការច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន និងអនុវត្តវិធានការពិន័យ អន្តរការណ៍លើបទល្មើសពាក់ព័ន្ធនឹងការបោះចោល ឬទុកដាក់សំរាម សំណល់រឹងទីប្រជុំជនបែប អាណាធិបតេយ្យ នៅទីសាធារណៈ និងទីតាំងឯកជនមិនបានត្រឹមត្រូវ ។

### ៥.២.៣- វិធានការរយៈពេលវែង (៦-១០ ឆ្នាំ)

- អនុវត្តពេញលេញនូវកម្មវិធីញែកសំរាម សំណល់រឹងទីប្រជុំជន ចាប់ពីដើមខ្សែដល់ចុងខ្សែ ជាមួយនឹងការដឹកជញ្ជូនដាច់ដោយឡែកពីគ្នា
- ពង្រឹងប្រសិទ្ធភាពអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ជាពិសេស វិធានការ ពិន័យអន្តរការណ៍លើបទល្មើសពាក់ព័ន្ធនឹងការបោះចោល ឬទុកដាក់សំរាម សំណល់រឹង ទីប្រជុំជនបែបអាណាធិបតេយ្យ នៅទីសាធារណៈ និងទីតាំងឯកជន ។

## ៥.៣- ការកំណត់ជម្រើសបច្ចេកទេស, បច្ចេកវិទ្យា និងហេដ្ឋារចនាសម្ព័ន្ធសមស្រប សម្រាប់កាត់បន្ថយការ បង្កើតសំរាម សំណល់រឹងទីប្រជុំជន

យុទ្ធសាស្ត្រនេះនឹងត្រូវបានអនុវត្តតាមរយៈវិធានការគោលនយោបាយដូចខាងក្រោម៖

### ៥.៣.១- វិធានការរយៈពេលខ្លី (១-២ ឆ្នាំ)

- ផ្តល់ការគាំទ្របច្ចេកទេស និងការកៀរគរថវិកាពីប្រភពនានា ដើម្បីពង្រឹងប្រសិទ្ធភាពការផ្តល់ សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចាប់ផ្តើមអនុវត្តការញែកសំរាម សំណល់រឹងទីប្រជុំជននៅតាមប្រភពបង្កើតសំរាម និងដោយមាន ការរៀបចំការប្រមូល និងការដឹកជញ្ជូនសំរាម សំណល់រឹងទាំងនេះ ដាច់ដោយឡែកពីគ្នា

- សិក្សាជម្រើស និងប្រើប្រាស់បច្ចេកទេស និងបច្ចេកវិទ្យាសមស្របសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដែលជានាទាំងប្រសិទ្ធភាព, គុណភាព និងតម្លៃ ជាពិសេសក្នុងការទាញយកធនធានពីសំណល់ និងការបំប្លែងសំណល់ជាថាមពល
- រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងព័ត៌មាន ព្រមទាំងធ្វើបច្ចុប្បន្នភាពអំពីបរិមាណ និងសមាសភាពសំរាម សំណល់រឹងទីប្រជុំជន
- រៀបចំបង្កើតស្ថានីយផ្ទេរ ដោយគិតគូរពីលទ្ធភាពភ្ជាប់ជាមួយនូវមជ្ឈមណ្ឌលញែក និងកែច្នៃបឋម សម្រាប់រាជធានី, ក្រុង និងស្រុក
- រៀបចំបង្កើតទីតាំងទាញយកធនធានពីសំណល់ និង
- រៀបចំបង្កើតទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយអនាម័យ ។

### ៥.៣.២- វិធានការរយៈពេលមធ្យម (៣-៥ ឆ្នាំ)

- ប្រើប្រាស់បច្ចេកទេស និងបច្ចេកវិទ្យាសមស្របក្នុងការបញ្ឈប់ ឬកែលម្អ ទីលានទុកដាក់ចុងក្រោយសំរាម សំណល់រឹងទីប្រជុំជន ដែលមិនមានលទ្ធភាពប្រើប្រាស់បន្ត ឬបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់សង្គម និងបរិស្ថាន
- ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធវៃឆ្លាតសម្រាប់គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន (Intelligent Municipal Solid Waste Management System)
- រៀបចំបង្កើតស្ថានីយញែកសំរាម សំណល់រឹងទីប្រជុំជននៅតាមមូលដ្ឋានរាជធានី, ក្រុង និងស្រុក សម្រាប់រាជធានី, ក្រុង និងស្រុក
- កែលម្អទីតាំងកែច្នៃសំរាម សំណល់រឹងទីប្រជុំជននៅតាមមូលដ្ឋានរាជធានី, ក្រុង និងស្រុក និងលើកទឹកចិត្តដល់ផ្នែកឯកជន និងអង្គការមិនមែនរដ្ឋាភិបាលឱ្យចូលរួមធ្វើសកម្មភាពក្នុងវិស័យកែច្នៃសំណល់ ព្រមទាំងលើកកម្ពស់ការប្រើប្រាស់ផលិតផល ដែលកែច្នៃចេញពីសំណល់ ដើម្បីឱ្យដំណើរការកែច្នៃអាចប្រព្រឹត្តទៅបានពេញលេញ និង
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការថ្នាក់ជាតិ, តំបន់ និងអន្តរជាតិពាក់ព័ន្ធនឹងបច្ចេកទេស និងបច្ចេកវិទ្យាក្នុងការគ្រប់គ្រងសំរាម សំណល់រឹងនៅទីប្រជុំជន ។

### ៥.៣.៣- វិធានការរយៈពេលវែង(៦-១០ ឆ្នាំ)

- សិក្សាជម្រើសនៃការប្រើប្រាស់បច្ចេកវិទ្យាថ្មីបន្ថែមទៀត
- បន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការថ្នាក់ជាតិ, តំបន់ និងអន្តរជាតិពាក់ព័ន្ធនឹងបច្ចេកទេស និងបច្ចេកវិទ្យាថ្មីៗក្នុងការគ្រប់គ្រងសំរាម សំណល់រឹងនៅទីប្រជុំជន ។

## ៥.៤- ការបង្កើតឱកាសវិនិយោគដល់វិស័យឯកជន លើការផ្តល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

យុទ្ធសាស្ត្រនេះនឹងត្រូវបានអនុវត្តតាមរយៈវិធានការគោលនយោបាយដូចខាងក្រោម៖

### ៥.៤.១- វិធានការរយៈពេលខ្លី (១-២ ឆ្នាំ)

- ផ្តល់ឱកាស និងភាពងាយស្រួលដល់វិស័យឯកជន ក្នុងការចូលរួមក្នុងគ្រប់ខ្សែច្រវាក់នៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រួមមាន៖ ការសម្អាត, ការប្រមូល និងដឹកជញ្ជូន, ការញែក, ការធ្វើប្រព្រឹត្តិកម្ម, ការកែច្នៃ និងការទាញយកធនធានឡើងវិញពីសំណល់
- បែងចែកជាផ្នែក ឬវិស័យសម្រាប់ការចូលរួមវិនិយោគពីវិស័យឯកជន ដែលអនុញ្ញាតឱ្យដៃគូផ្សេងៗទៀតអាចចូលរួមបានក្នុងផ្នែកមួយ ឬច្រើននៃខ្សែច្រវាក់តាមរយៈការប្រកួតប្រជែងប្រកបដោយតម្លាភាព និងប្រសិទ្ធភាព
- ជំរុញឱ្យមានការចូលរួមឱ្យបានច្រើនពីសំណាក់ក្រុមហ៊ុនដែលផ្តល់សេវាសម្អាត, ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ដើម្បីធានាបាននូវយន្តការនៃការប្រកួតប្រជែងសម្រាប់រាជធានី, ក្រុង និងស្រុក (ទៅតាមបរិមាណ និងដង់ស៊ីតេប្រជាពលរដ្ឋខ្ពស់)
- ចាប់ផ្តើមយុទ្ធនាការអនុវត្តកម្មវិធីញែកសំរាម សំណល់រឹងទីប្រជុំជន ទៅតាមប្រភេទនៅតាមទីតាំងសំខាន់ៗ ជាអាទិ៍៖ អគាររដ្ឋបាលសាធារណៈ, មជ្ឈមណ្ឌលពាណិជ្ជកម្ម, មណ្ឌលកំសាន្ត, សណ្ឋាគារ និងនៅតាមសហគមន៍ ។ ល ។

### ៥.៤.២- វិធានការរយៈពេលមធ្យម (៣-៥ ឆ្នាំ)

- ជំរុញការអនុវត្តប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមវិធានការចម្រុះ ដើម្បីប្រែក្លាយសំរាម សំណល់រឹងទីប្រជុំជន ឱ្យមានតម្លៃសេដ្ឋកិច្ច
- ជំរុញ និងលើកទឹកចិត្តដល់វិស័យឯកជនចូលរួមវិនិយោគលើការបំប្លែងសំរាម សំណល់រឹងទីប្រជុំជន ជាថាមពល, ការកែច្នៃ និងទាញយកធនធានពីសំរាម សំណល់រឹងទីប្រជុំជន
- លើកទឹកចិត្តដល់វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលនានាឱ្យចូលរួមធ្វើសកម្មភាពក្នុងវិស័យកែច្នៃសំរាម សំណល់រឹងទីប្រជុំជន ព្រមទាំងលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលផលិតចេញពីការកែច្នៃ
- ជំរុញ និងលើកទឹកចិត្តការបង្កើតឧស្សាហកម្មកែច្នៃសំរាម សំណល់រឹងទីប្រជុំជន
- លើកកម្ពស់កម្មវិធីកាត់បន្ថយការប្រើប្រាស់ថង់ និងសម្ភារប្លាស្ទិកប្រភេទមួយចំនួនដោយជំរុញការប្រើប្រាស់វត្ថុជំនួសដែលមិនបង្កផលប៉ះពាល់ដល់សុខភាពសាធារណៈ និងគុណភាពបរិស្ថាន
- បង្កើនកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីជាមួយភាគីពាក់ព័ន្ធ ដើម្បីស្វែងរកជំនួយសម្រាប់ការផ្តល់ហិរញ្ញប្បទានដល់គម្រោងអភិវឌ្ឍន៍ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ។

### ៥.៤.៣- វិធានការរយៈពេលវែង (៦-១០ ឆ្នាំ)

- បង្កើតភាពជាដៃគូ និងលើកទឹកចិត្តដល់វិស័យឯកជនចូលរួមវិនិយោគលើការបំប្លែងសំរាម សំណល់រឹងទីប្រជុំជន ជាថាមពល, ការកែច្នៃ និងទាញយកធនធានពីសំរាម សំណល់រឹងទីប្រជុំជន
- លើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន និងការទទួលខុសត្រូវរបស់ផលិតករ លើសំរាម សំណល់រឹងទីប្រជុំជន ពីច្រវាក់ផលិតកម្មរបស់ខ្លួន (Extended Producer Responsibility)

- ជំរុញ និងលើកទឹកចិត្តឱ្យមានការគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធ តាមរយៈការបង្កើតភាពជាដៃគូជិតស្និទ្ធ ដើម្បីធានាឱ្យការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដំណើរការប្រកបដោយប្រសិទ្ធភាព
- ជំរុញ និងផ្តល់ឱកាសដល់វិស័យឯកជនប្រើប្រាស់នូវបច្ចេកវិទ្យាទំនើប តាមរយៈការបំពាក់នូវគ្រឿងបរិក្ខារស្វ័យប្រវត្តិកម្ម ដើម្បីសម្រួលដល់ការប្រតិបត្តិគម្រោង និងប្រើប្រាស់ពលកម្មតិច
- ជំរុញការចូលរួមអនុវត្តផែនការកាត់បន្ថយការបង្កើតសំរាម សំណល់រឹងទីប្រជុំជន នៅនឹងប្រភពបង្កើតជាពិសេសសំណល់ប្លាស្ទិក
- លើកកម្ពស់ការចូលរួមអនុវត្តវិធានការលុបបំបាត់ការប្រើប្រាស់ថង់ និងសម្ភារប្លាស្ទិកមួយចំនួនដែលមិនចាំបាច់ និងជំរុញការប្រើប្រាស់ផលិតផលផ្សេងជំនួស
- បន្តកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីដើម្បីស្វែងរកជំនួយបច្ចេកទេស និង ហិរញ្ញប្បទានសម្រាប់គម្រោងអភិវឌ្ឍន៍នានាពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ។

## ៥.៥- ការលើកកម្ពស់ការអប់រំ, ការផ្សព្វផ្សាយ និងការជំរុញឱ្យមានការចូលរួមពីសាធារណជនអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

យុទ្ធសាស្ត្រនេះនឹងត្រូវបានអនុវត្តតាមរយៈវិធានការគោលនយោបាយដូចខាងក្រោម៖

### ៥.៥.១- វិធានការរយៈពេលខ្លី (១-២ ឆ្នាំ)

- រៀបចំកម្មវិធីអប់រំ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយដើម្បីលើកកម្ពស់ការធ្វើអនាម័យតាមគេហដ្ឋាន និងទីតាំងរបស់ខ្លួន ដោយអនុវត្តតាមគោលការណ៍ **"ម្ចាស់ទីតាំងទទួលខុសត្រូវចំពោះសំរាម សំណល់រឹងនៅមុខទីតាំងរបស់ខ្លួន"** និងពង្រីកចំណេះដឹងសាធារណៈអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ជាពិសេស យុទ្ធនាការអប់រំដល់ប្រជាពលរដ្ឋ ក្នុងការបង្កើនការយកចិត្តទុកដាក់ ការទទួលខុសត្រូវក្នុងនាមជាពលរដ្ឋល្អ និងការផ្លាស់ប្តូរទំលាប់នៃការប្រមូលសំរាម សំណល់រឹងទីប្រជុំជន យកទៅដុតចោល ដែលបង្កផលប៉ះពាល់ដល់គុណភាពខ្យល់អាកាស និងសុខភាពសាធារណៈ
- ផ្សព្វផ្សាយអំពីកាតព្វកិច្ចអ្នកប្រើប្រាស់សេវាសម្អាត, ប្រមូល, ដឹកជញ្ជូន និងសេវាទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅទីលាន ក្នុងការចូលរួមបង់កម្រៃសេវា បានត្រឹមត្រូវ និងទាន់ពេលវេលា
- អប់រំ និងផ្សព្វផ្សាយអំពីវិធានការ, ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះចោលសំរាម សំណល់រឹងទីប្រជុំជនមិនបានត្រឹមត្រូវតាមការកំណត់របស់រដ្ឋបាលមូលដ្ឋាន
- លើកកម្ពស់ការអប់រំ និងការផ្សព្វផ្សាយតាមគ្រប់រូបភាពដល់សាធារណជនអំពីសារប្រយោជន៍នៃការញែកសំរាម សំណល់រឹងទីប្រជុំជន, អំពីកម្មវិធីកាត់បន្ថយការបង្កើតការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានមកពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន ។

### ៥.៥.២-វិធានការរយៈពេលមធ្យម និងវែង (៣-១០ ឆ្នាំ)

- ដាក់បញ្ចូលកម្មវិធីអនាម័យបរិស្ថានទៅក្នុងកម្មវិធីសិក្សានៅតាមគ្រឹះស្ថានអប់រំគ្រប់ជាន់ថ្នាក់

- បន្តអប់រំ និងផ្សព្វផ្សាយអំពីវិធានការ, ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះចោលសំរាម សំណល់រឹងទីប្រជុំជន មិនបានត្រឹមត្រូវតាមការកំណត់របស់រដ្ឋបាលមូលដ្ឋាន
- រៀបចំ និងបង្កើតយន្តការប្រឡងប្រណាំង និងការលើកទឹកចិត្តនានាពាក់ព័ន្ធនឹងការប្រតិបត្តិល្អក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ។

## ៦-ផែនការសកម្មភាព និងដំណើរការអនុវត្តគោលនយោបាយ

ក្នុងដំណើរការនៃការអនុវត្តគោលនយោបាយនេះ ត្រូវរៀបចំជាផែនការសកម្មភាពសម្រាប់ការងារនីមួយៗដែលចែកជាផែនការសកម្មភាពរយៈពេលខ្លី, រយៈពេលមធ្យម និងរយៈពេលវែង ដោយមានការសិក្សាស្រាវជ្រាវ និងពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ដើម្បីទទួលបានការគាំទ្រ និងធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ។

ដើម្បីសម្រេចបានយុទ្ធសាស្ត្រខាងលើ ផែនការសកម្មភាពអាទិភាពជាគោលសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដែលត្រូវអនុវត្ត មានជាអាទិ៍៖

### ៦.១- ការរៀបចំយន្តការស្ថាប័ន និងការបង្កើតក្របខណ្ឌគតិយុត្ត

#### ៦.១.១- ថ្នាក់ជាតិ

គណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដែលដឹកនាំដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអនុប្រធាន ព្រមទាំងមានការចូលរួម ជាសមាជិកពីក្រសួង-ស្ថាប័ន ពាក់ព័ន្ធមានតួនាទីដូចខាងក្រោម៖

- រៀបចំគោលនយោបាយ, យុទ្ធសាស្ត្រ, ផែនការសកម្មភាព និងយន្តការតាមដានការអនុវត្ត
- កសាងក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
- គិតគូរអំពីយន្តការលើកទឹកចិត្តនានាដល់ការវិនិយោគលើវិស័យនេះ(តាមទម្រង់ណាមួយដែលសមស្រប និងប្រកបដោយប្រសិទ្ធភាពខ្ពស់) រួមទាំងមានការលើកទឹកចិត្តឱ្យមានការប្រើប្រាស់ផលិតផលដែលមានផលប៉ះពាល់តិច ឬ គ្មានដល់គុណភាពបរិស្ថាន ដើម្បីកាត់បន្ថយការប្រើប្រាស់ផលិតផលណាដែលនាំឱ្យមានផលប៉ះពាល់ខ្លាំងដល់បរិស្ថាន
- សិក្សាបទពិសោធន៍ជាក់ស្តែងកន្លងមក និងបទពិសោធន៍របស់បណ្តាប្រទេសនានាក្នុងតំបន់ ឬប្រទេសអភិវឌ្ឍន៍ដទៃទៀតដែលមានឧត្តមានុវត្តន៍ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រួមទាំងការបំប្លែងសំរាម សំណល់រឹងទីប្រជុំជន ជាថាមពល, ការកែច្នៃ និងទាញយកធនធានពីសំរាម សំណល់រឹងទីប្រជុំជន
- លើកអនុសាសន៍ជាវិធានការ និងដឹកនាំ, សម្របសម្រួល ព្រមទាំងតាមដាន, វាយតម្លៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងការអនុវត្តការកែទម្រង់នៃការគ្រប់គ្រងក្រុមហ៊ុនប្រមូលសំរាម សំណល់រឹងទីប្រជុំជននាពេលបច្ចុប្បន្ន, យន្តការនៃការបង់ថ្លៃសេវា និងការកំណត់នីតិវិធីដោះស្រាយបញ្ហាច្បាស់លាស់ជាស្ថាពរ

- ធ្វើយុទ្ធនាការអប់រំ និងផ្សព្វផ្សាយទ្រង់ទ្រាយធំទូទាំងប្រទេស សំដៅកែប្រែឥរិយាបថរបស់ប្រជាពលរដ្ឋ ។ ទន្ទឹមនេះ ក្រសួង-ស្ថាប័ន ជាសមាជិកគណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ត្រូវធ្វើជាគំរូដោយត្រូវដាក់ចេញនូវវិធានការដាក់លាក់នានា ដើម្បីគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងចូលរួមអភិរក្សបរិស្ថាន ។

### ៦.១.២- ថ្នាក់ក្រោមជាតិ

រដ្ឋបាលរាជធានី, ក្រុង និងស្រុក ត្រូវអនុវត្តសកម្មភាពអាទិភាពជាគោល ដូចខាងក្រោម៖

- បង្កើតអង្គភាព ឬ ការិយាល័យចំណុះរដ្ឋបាលថ្នាក់រាជធានី, ក្រុង និងស្រុក ក្នុងការទទួលខុសត្រូវអនុវត្តការផ្ទេរមុខងារក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដែលមានភារកិច្ចជាអាទិ៍៖ ការរៀបចំផែនការសកម្មភាព ផែនការប្រតិបត្តិការការធ្វើសារពើភណ្ឌអំពីប្រភេទ, ប្រភព និងបរិមាណសំរាម សំណល់រឹងទីប្រជុំជន ដែលបានបង្កើតប្រចាំថ្ងៃ និងការគ្រប់គ្រងទិន្នន័យ ។ ល ។
- បង្កើតយន្តការផ្តល់សេវាសម្អាត, ប្រមូល, ដឹកជញ្ជូន និងទុកដាក់សំរាម សំណល់រឹងទីប្រជុំជន នៅទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន
- ជំរុញឱ្យមានការចូលរួមឱ្យបានច្រើនពីសំណាក់ក្រុមហ៊ុនដែលផ្តល់សេវាសម្អាត, ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ដើម្បីធានាបាននូវយន្តការនៃការប្រកួតប្រជែងសម្រាប់រាជធានី, ក្រុង និងស្រុក (ទៅតាមបរិមាណ និងដង់ស៊ីតេប្រជាពលរដ្ឋខ្ពស់)
- រៀបចំបទប្បញ្ញត្តិដែលកំណត់ និងបែងចែកតំបន់ដែលត្រូវសម្អាត, ប្រមូល, ដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន និងដាក់ដេញថ្លៃទៅតាមតំបន់ ដើម្បីឱ្យមានការប្រកួតប្រជែងគ្នា និងចៀសវាងការផ្តាច់មុខ
- រៀបចំកំណត់លិខិតបទដ្ឋានគតិយុត្តក្នុងការផ្ទេរមុខងារប្រតិបត្តិការសេវាសម្អាត, ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ទៅឱ្យវិស័យឯកជននៅក្នុងកិច្ចសន្យាចាំបាច់ត្រូវបញ្ចូលនូវសូចនាករ សមិទ្ធកម្មសំខាន់ៗ ដែលកំណត់ដោយគណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- រៀបចំលិខិតបទដ្ឋានគតិយុត្ត ដោយមានការកំណត់រយៈពេលច្បាស់លាស់នៅក្នុងកិច្ចសន្យាផ្តល់សេវាសម្អាត, ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន
- រៀបចំគោលការណ៍ណែនាំ អនុវត្តការញែកសំរាម សំណល់រឹងទីប្រជុំជន និងដឹកជញ្ជូនដោយឡែកទៅតាមប្រភេទ
- រៀបចំនីតិវិធី និងវិធានការច្បាប់លិខិតបទដ្ឋានគតិយុត្តជាធរមាន និងអនុវត្តវិធានការពិន័យអន្តរការណ៍លើបទល្មើសពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន ។

## ៦.២- ការកសាងសមត្ថភាព និងការបណ្តុះបណ្តាលធនធានមនុស្ស

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រខាងលើ ត្រូវយកចិត្តទុកដាក់លើ៖

- ការអភិវឌ្ឍសមត្ថភាពបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំផែនការ, ការរចនា, ការសាងសង់ និងការគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន និងការផ្តល់សេវាកម្ម

- ការបណ្តុះបណ្តាលធនធានមនុស្សលើចំណេះដឹងខាងបច្ចេកទេស, បច្ចេកវិទ្យានៃការកែច្នៃ និង ការទាញយកធនធានឡើងវិញពីសំរាម សំណល់រឹងទីប្រជុំជន
- ការបណ្តុះបណ្តាលលើកកម្ពស់ស្មារតីនៃការស្រលាញ់អនាម័យបរិស្ថាន និងលើកកម្ពស់ការយល់ដឹង ពីសុវត្ថិភាពនៃការទុកដាក់សំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន ។

## ៧- យន្តការហិរញ្ញប្បទាន

ដើម្បីគាំទ្រការអនុវត្តគោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ២០២០-២០៣០ ត្រូវមានធនធានហិរញ្ញវត្ថុដែលបានមកពី៖

- ថវិកាទទួលបានពីការបង់ថ្លៃសេវាដោយអ្នកប្រើប្រាស់សេវាសម្អាត, ប្រមូល, ដឹកជញ្ជូន និងទុកដាក់ សំរាម សំណល់រឹងទីប្រជុំជន នៅទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលកំណត់ ដោយរដ្ឋបាលរាជធានី, ក្រុង និងស្រុក ដើម្បីបំពេញតាមការចំណាយ ស្របតាមគោលការណ៍ «អ្នកបំពុលត្រូវបង់ថ្លៃ»
- ថវិកាអន្តរាគមន៍ពីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ មូលនិធិបរិស្ថាន និងសង្គម
- ថវិកាអន្តរាគមន៍របស់រាជរដ្ឋាភិបាល ដែលអាចនឹងត្រូវផ្តល់សម្រាប់ការសាងសង់ស្ថានីយផ្ទេរ, ទីតាំងធ្វើប្រព្រឹត្តិកម្ម និងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនប្រកបដោយអនាម័យ និងសុវត្ថិភាពបរិស្ថាន
- អំណោយ និងវិភាគទានពីដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, វិស័យឯកជន និងពី សប្បុរសជននានា
- ការវិនិយោគដែលទទួលបានការលើកទឹកចិត្តពីរាជរដ្ឋាភិបាល ចំពោះការបំប្លែងសំរាម សំណល់រឹង ទីប្រជុំជន ជាថាមពល, ការកែច្នៃ និងទាញយកធនធានពីសំរាម សំណល់រឹងទីប្រជុំជន ។

## ៨- ការគ្រប់គ្រងហានិភ័យ

ដើម្បីត្រៀមដោះស្រាយ និងគ្រប់គ្រងហានិភ័យនានាដែលអាចកើតមានឡើងនៅក្នុងការអនុវត្ត វិធានការទាំងនេះ រាជរដ្ឋាភិបាលបានកំណត់នូវទិសដៅសំខាន់ៗមួយចំនួន រួមមានជាអាទិ៍៖

- ការពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តិ ពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹង ទីប្រជុំជនគឺទាមទារនូវភាពម៉ឺងម៉ាត់ និងហ្មត់ចត់ ប៉ុន្តែដោយសារស្ថានភាពនៃការយល់ដឹង, ការ រស់នៅ និងការចូលរួមរបស់ប្រជាពលរដ្ឋនៅមានកម្រិត ដូច្នេះនៅក្នុងការអនុវត្តមុខងារ គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននេះ រដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវមានភាពទន់ភ្លន់ និង បត់បែនទៅតាមស្ថានភាពជាក់ស្តែងផងដែរ
- នៅក្នុងប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដែលគិតចាប់ពីប្រភពនៃការបង្កើតរហូត ដល់ការទុកដាក់ចុងក្រោយនៃសំរាម សំណល់រឹងទីប្រជុំជននេះ ហិរញ្ញវត្ថុគឺជាបញ្ហាប្រឈមចម្បង មួយ ក្នុងចំណោមបញ្ហាចម្បងនានា ។ ការរៀបចំប្រព័ន្ធសម្អាត, ប្រមូល, ដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន និងការពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវានេះ ទាមទារនូវការប៉ះប៉ូវចំណាយ ជាចម្បងដោយអ្នកបង្កើតសំរាម សំណល់រឹងទីប្រជុំជន ផ្ទាល់តាមរយៈការបង់ថ្លៃសេវា និង

ឧបត្ថម្ភធនពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ និងប្រភពផ្សេងៗ ។ ដើម្បីកាត់បន្ថយសម្ពាធនៃការរ៉ាប់រងចំណាយ រដ្ឋបាលមូលដ្ឋានចាំបាច់ត្រូវសម្រេចឱ្យបាននូវយន្តការដែលជំរុញការទាញយកធនធានពីសំរាម សំណល់រឹងទីប្រជុំជន និងកាត់បន្ថយបរិមាណយកទៅចាក់ចោលនៅទីលានឱ្យបានជាអតិបរមា ។ ការរៀបចំនូវហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងផ្សេងៗ ជាពិសេសទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនប្រកបដោយអនាម័យ, សុវត្ថិភាពបរិស្ថាន និងការបំពាក់ឡដុតសំរាម សំណល់រឹងទីប្រជុំជន ចាំបាច់ត្រូវមានថវិកាគាំទ្រផងដែរ ។ ដូចនេះ ថ្វីត្បិតតែការអនុវត្តនូវគោលការណ៍អ្នកបំពុលត្រូវបង់ថ្លៃ គឺជាវិធានការគ្រឹះដែលត្រូវអនុវត្តក៏ដោយ ក៏ការផ្តល់នូវថវិកាអន្តរាគមន៍របស់រាជរដ្ឋាភិបាល ត្រូវតែជានានូវនិរន្តរភាពផងដែរ ។

## ៩- ស្ថាប័នទទួលខុសត្រូវលើការអនុវត្តគោលនយោបាយគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងការចូលរួមពីអ្នកពាក់ព័ន្ធ

ដើម្បីអនុវត្តគោលនយោបាយនេះសម្រេចបានជោគជ័យដូចបានរំពឹងទុក និងប្រកបដោយប្រសិទ្ធភាព, ប្រសិទ្ធិផល និងតម្លាភាព ចាំបាច់ត្រូវមានស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងអនុវត្តដូចខាងក្រោម៖

### ៩.១- រដ្ឋបាលថ្នាក់ជាតិ

#### ៩.១.១- គណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- ទទួលខុសត្រូវក្នុងការតាមដាន, វាយតម្លៃ និងសម្របសម្រួលការអនុវត្តគោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ២០២០-២០៣០ ដើម្បីធានាសង្គតិភាព និងប្រសិទ្ធភាព ។

#### ៩.១.២- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- រៀបចំបែងចែកថវិកាអន្តរាគមន៍របស់រាជរដ្ឋាភិបាលសម្រាប់ឧបត្ថម្ភធន ដើម្បីបំពេញចន្លោះខ្វះខាតដល់ប្រតិបត្តិការសេវាសម្អាត, ប្រមូល, ដឹកជញ្ជូន និងទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ការសាងសង់ស្ថានីយផ្ទេរសំរាម សំណល់រឹងទីប្រជុំជន ទីតាំងធ្វើប្រព្រឹត្តិកម្ម និងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយអនាម័យ និងសុវត្ថិភាពបរិស្ថាន ដល់រដ្ឋបាលរាជធានី, ក្រុង និងស្រុក ព្រមទាំងកៀរគរប្រភពថវិកាពីដៃគូអភិវឌ្ឍន៍នានា, ពីវិស័យឯកជន និងពីប្រភពផ្សេងទៀតសម្រាប់អនុវត្តគម្រោង ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ។
- រៀបចំ និងដោះស្រាយបញ្ហាពាក់ព័ន្ធនឹងយន្តការហិរញ្ញវត្ថុគាំទ្រដល់ការអនុវត្ត នូវគោល-នយោបាយនេះ បង្កើនកញ្ចប់ថវិកាសេវាអនាម័យបរិស្ថានសម្រាប់គាំទ្រដល់ការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងកៀរគរប្រភពថវិកាពីដៃគូអភិវឌ្ឍន៍នានា និងពីផ្នែកឯកជន សម្រាប់អនុវត្តគម្រោង ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ។

## ៩.១.៣- ក្រសួងមហាផ្ទៃ និង គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

- មានតួនាទីជំរុញដល់កិច្ចប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចគាំទ្រ និងសហការជាមួយក្រសួងបរិស្ថាន និងអ្នកពាក់ព័ន្ធនានាក្នុងការអភិវឌ្ឍសមត្ថភាព និងការចែករំលែកបទពិសោធន៍អំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ។
- ជាមួយគ្នានេះត្រូវធ្វើការសម្របសម្រួល និងកៀរគរការគាំទ្រនានាទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ព្រមទាំងផ្តល់ការអន្តរាគមន៍ក្នុងការតាមដាន, ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ។

## ៩.១.៤- ក្រសួងបរិស្ថាន

- ដឹកនាំ និងសម្របសម្រួលរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីអនុវត្តគោលនយោបាយនេះ
- ផ្តល់ការគាំទ្រជំនាញបច្ចេកទេសដល់រដ្ឋបាលមូលដ្ឋានដើម្បីអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព
- សហការរវាងក្រសួង-ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីស្វែងរកការគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ក្នុងការធ្វើឱ្យប្រសើរឡើងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីដើមខ្សែដល់ចុងខ្សែ រួមបញ្ចូលទាំងទីលានទុកដាក់ចុងក្រោយសំរាម សំណល់រឹងទីប្រជុំជន
- ពិនិត្យ វាយតម្លៃ និងសម្រេចលើបច្ចេកទេសរៀបចំទីលាន វិធានការការពារបរិស្ថានក្នុងពេលដំណើរការ និងពេលបិទបញ្ចប់ការប្រើប្រាស់ទីលាន និងរយៈពេលនៃការប្រើប្រាស់ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន
- សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការត្រួតពិនិត្យ វាយតម្លៃការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

## ៩.១.៥- ក្រសួងទេសចរណ៍ និង គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត (គ.ជ.វ.ទ)

- ដឹកនាំការអនុវត្តស្របទៅតាមតួនាទីរបស់គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាតក្នុងគោលបំណងធ្វើការវាយតម្លៃទីក្រុងស្អាតដើម្បីលើកកម្ពស់សោភ័ណភាព អនាម័យបរិស្ថានល្អនៅតាមបណ្តារាជធានី, ក្រុង និងស្រុក នៃព្រះរាជាណាចក្រកម្ពុជាឱ្យក្លាយជាគោលដៅទេសចរណ៍ដ៏ល្អ និងធ្វើឱ្យកម្ពុជាក្លាយជាគោលដៅបៃតង (Green Destination) ដែលមានភាពទាក់ទាញ និងប្រកបដោយភាពកក់ក្តៅ ។

## ៩.១.៦- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- លើកកម្ពស់ និងគាំទ្រដល់សហគ្រាស ឬអ្នកផលិតដែលបានអនុវត្តគម្រោងពាក់ព័ន្ធ ដល់ការ

កាត់បន្ថយសំរាម សំណល់រឹងទីប្រជុំជន ដោយដាក់បញ្ចូលនូវកម្មវិធីផលិតកម្មស្អាត និងការអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងបរិស្ថាន ISO14001 ។

- អនុវត្តផែនការសម្រាប់បង្កើតឧស្សាហកម្មបៃតង រួមបញ្ចូលទាំងឧស្សាហកម្មកែច្នៃសំរាម សំណល់រឹងទីប្រជុំជន ។

### ៩.១.៧- ក្រសួងរ៉ែ និងថាមពល

- ដឹកនាំ និងសម្របសម្រួលរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងៗ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការសិក្សាពីសមិទ្ធិលទ្ធភាពសម្រាប់ការវិនិយោគការបំប្លែងសំរាម សំណល់រឹងទីប្រជុំជនជាថាមពល, ការកែច្នៃ និងទាញយកធនធានពីសំរាម សំណល់រឹងទីប្រជុំជន
- ជំរុញគម្រោងវិនិយោគ នៃការបំប្លែងសំរាម សំណល់រឹងទីប្រជុំជន ជាថាមពល សម្រាប់ រាជធានី, ក្រុង និងស្រុក និងបណ្តាទីប្រជុំជនដែលមានសក្តានុពលសេដ្ឋកិច្ច និងពុំមានដីសម្រាប់រៀបចំទីលានទុកដាក់ចាក់សំរាម សំណល់រឹងទីប្រជុំជន ។

### ៩.១.៨- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- សហការជាមួយក្រសួងបរិស្ថាន ក្នុងការណែនាំអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនឱ្យបានត្រឹមត្រូវតាមគោលការណ៍សុវត្ថិភាពបរិស្ថាននៅតាមតំបន់ឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេស
- ជំរុញ និងលើកទឹកចិត្តចំពោះគម្រោងវិនិយោគពាក់ព័ន្ធនឹងបច្ចេកវិទ្យាថ្មីៗ ដែលបង្កើតសំណល់តិច, ការកែច្នៃ និងការទាញយកធនធានពីសំរាម សំណល់រឹងទីប្រជុំជន ឬការបំប្លែងជាថាមពល ។

### ៩.១.៩- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- រៀបចំចុះបញ្ជីប្រើប្រាស់ដីដោយឡែកសម្រាប់តំបន់ដែលត្រូវបានជ្រើសរើសសាងសង់ជាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ដោយមិនត្រូវអនុញ្ញាត ឱ្យមានការសាងសង់សំណង់ផ្សេងចម្ងាយមួយគីឡូម៉ែត្រនៅជុំវិញទីតាំងដែលបានស្នើសុំ ។

### ៩.១.១០- ក្រសួងសាធារណការ និងដឹកជញ្ជូន

- សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការកៀរគរប្រភពថវិកាពីដៃគូអភិវឌ្ឍន៍នានា សម្រាប់អនុវត្តវិនិយោគគម្រោងសាងសង់ជាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយអនាម័យនៅតាមរាជធានី, ក្រុង, ស្រុក និងទីប្រជុំជននានា ។

### ៩.១.១១- ក្រសួងធនធានទឹក និងឧតុនិយម

- ចូលរួមសិក្សា និងផ្តល់យោបល់លើផលប៉ះពាល់ផ្នែកធនធានធារាសាស្ត្រលើទីតាំងស្នើសុំសាងសង់ជាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយអនាម័យ និងគុណភាពបរិស្ថាន ។

### ៩.១.១២- ក្រសួងព័ត៌មាន

- ខិតខំបង្កើនការផ្សព្វផ្សាយនូវព័ត៌មានដើម្បីបង្កើនចំណេះដឹង ដល់សាធារណជនពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន និងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសោភ័ណភាព, អនាម័យ និងសុវត្ថិភាពបរិស្ថាន ។

### ៩.១.១៣- ក្រសួងអប់រំ យុវជន និងកីឡា

- ចងក្រង និងបញ្ចូលមេរៀនស្តីពីអនាម័យបរិស្ថានទៅក្នុងកម្មវិធីសិក្សាគ្រប់ជាន់ថ្នាក់ ។ ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន អាចជាកម្មវត្ថុមួយសម្រាប់កម្មវិធីអប់រំទូទៅ ហើយកម្មវិធីនេះនឹងទទួលបានប្រសិទ្ធភាពខ្ពស់ ប្រសិនបើមានការចូលរួមពីសិស្សានុសិស្សទូទាំងប្រទេស
- សិស្សានុសិស្ស និងនិស្សិត អាចជួយបន្តការផ្សព្វផ្សាយដល់ក្រុមគ្រួសារ ឬមិត្តភក្តិរបស់ពួកគេឱ្យទទួលយកចំណេះដឹង និងចូលរួមនៅក្នុងគ្រប់សកម្មភាពសង្គមក្នុងការជំរុញអនុវត្តកម្មវិធីប្រើប្រាស់ឡើងវិញ និងការកាត់បន្ថយការបង្កើតសំរាម សំណល់រឹងទីប្រជុំជន ។

### ៩.១.១៤- អគ្គិសនីកម្ពុជា

- សម្របសម្រួលរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងៗបង្កលក្ខណៈងាយស្រួល ដល់ការជំរុញការអនុវត្តគម្រោងវិនិយោគសាងសង់រោងចក្របំប្លែងសំរាម សំណល់រឹងទីប្រជុំជនជាថាមពល ។

## ៩.២- រដ្ឋបាលថ្នាក់ក្រោមជាតិ

- រៀបចំការអនុវត្តគោលការណ៍ ៣អ៊ែ នៃការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន ដោយផ្អែកលើគោលការណ៍ណែនាំបច្ចេកទេសពីក្រសួងបរិស្ថាន ។ ដើម្បីឱ្យការអនុវត្តគោលការណ៍ ៣អ៊ែ ទទួលបានជោគជ័យ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបង្កើតឱ្យមានការបែងចែកសំរាម សំណល់រឹងទីប្រជុំជន នៅនឹងប្រភពនៃការបង្កើតសំរាម សំណល់រឹងទីប្រជុំជន តាមរយៈការរៀបចំឱ្យមានធុងដាក់សំរាម សំណល់រឹងទីប្រជុំជន ផ្សេងពីគ្នា នៅតាមផ្ទះនៅតាមទីសាធារណៈ ដោយធ្វើការបែងចែកធុងសំរាម សំណល់រឹងទីប្រជុំជន ជាប្រភេទផ្សេងគ្នា ។ ល ។
- រៀបចំ និងបង្កើតមជ្ឈមណ្ឌលកែច្នៃសំរាម សំណល់រឹងទីប្រជុំជន និងការធ្វើជីកំប៉ុស្តិ៍ ។ ល ។
- យកចិត្តទុកដាក់ និងរៀបចំកម្មវិធីបណ្តុះបណ្តាល, ការអប់រំ និងផ្សព្វផ្សាយចំណេះដឹងដល់សាធារណជនអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយអនាម័យ និងសុវត្ថិភាពបរិស្ថាន ។

### ៩.២.១- រដ្ឋបាលរាជធានី ខេត្ត

- ទទួលខុសត្រូវសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រ និងសកម្មភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនជាលក្ខណៈតំបន់ ដោយរួមបញ្ចូលនូវយុទ្ធសាស្ត្រនៃការរៀបចំទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន
- រដ្ឋបាលរាជធានី, ខេត្ត ត្រូវលើកកម្ពស់ និងសម្របសម្រួលក្នុងការសាងសង់ទីលានទុកដាក់

សំរាម សំណល់រឹងទីប្រជុំជនជាលក្ខណៈអន្តររាជធានី, ក្រុង និងស្រុក (ទីលានប្រើរួមគ្នា) ។

### ៩.២.២- រដ្ឋបាលក្រុង ស្រុក

- ទទួលខុសត្រូវ និងអនុវត្តផ្ទាល់លើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងកម្មវិធីផ្សេងៗទៀតសំដៅធានាឱ្យការអភិវឌ្ឍនៅក្នុងមូលដ្ឋានរបស់ខ្លួនប្រកបដោយចីរភាព
- រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំសេចក្តីណែនាំនានា ឬផែនការសកម្មភាពសម្រាប់អនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅថ្នាក់មូលដ្ឋានតាមរយៈ ការពង្រឹងប្រសិទ្ធភាពក្រុមហ៊ុនផ្តល់សេវាសម្អាត, ប្រមូល និងដឹកជញ្ជូន សំរាម សំណល់រឹងទីប្រជុំជន ការរៀបចំស្ថានីយផ្ទេរបណ្តោះអាសន្ន, ការដឹកជញ្ជូន និងការធ្វើប្រព្រឹត្តិកម្មដោយរួមបញ្ចូល ទាំងសេចក្តីណែនាំស្តីពីការញែកសំរាម សំណល់រឹងទីប្រជុំជននៅនឹងប្រភពនៃការបង្កើតសំរាម សំណល់រឹងទីប្រជុំជន
- រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំយន្តការត្រួតពិនិត្យ អង្កេត និងពង្រឹងការដាក់ពិន័យយ៉ាងតឹងរ៉ឹង ចំពោះការបំពានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ។

## ៩.៣- អង្គការមិនមែនរដ្ឋាភិបាល

- អង្គការមិនមែនរដ្ឋាភិបាលមានតួនាទីសំខាន់ក្នុងការរួមចំណែកក្នុងកិច្ចគាំពារបរិស្ថាន និងសុខភាពសាធារណៈ
- ក្នុងបរិបទនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមវិធានការចម្រុះ អង្គការមិនមែនរដ្ឋាភិបាលអាចចែករំលែកការខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការស្វែងរកសហគមន៍អន្តរជាតិ, ប្រទេសផ្តល់ជំនួយនានាឱ្យគាំទ្រ និងអនុវត្តគម្រោងសាកល្បងដើម្បីបង្ហាញដល់សហគមន៍មូលដ្ឋាន និងជួយលើកកម្ពស់ការចូលរួមនៅក្នុងសកម្មភាពនេះឱ្យកាន់តែសកម្មថែមទៀត ។

## ៩.៤- វិស័យឯកជន

- វិស័យឯកជនមានតួនាទីសំខាន់ក្នុងការរួមចំណែកដល់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមរយៈការវិនិយោគលើការបង្កើតសេវាសម្អាត, ប្រមូល, ដឹកជញ្ជូន, ការធ្វើប្រព្រឹត្តិកម្ម និងទុកដាក់ចុងក្រោយសំរាម សំណល់រឹងទីប្រជុំជន
- វិស័យឯកជនមានតួនាទីសំខាន់ក្នុងការវិនិយោគលើការកែច្នៃ និងការទាញយកធនធានពីសំរាម សំណល់រឹងទីប្រជុំជន ឬការបំប្លែងជាថាមពលដើម្បីទាញយកធនធានសម្រាប់ការប្រើប្រាស់ឡើងវិញ និងសំដៅកាត់បន្ថយបរិមាណសំរាម សំណល់រឹងទីប្រជុំជនដែលត្រូវបោះចោល ។

## ៩.៥- ការចូលរួមពីសាធារណជន និងសហគមន៍មូលដ្ឋាន

- ចូលរួមអនុវត្តរាល់សេចក្តីណែនាំនានាដែលចេញដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជាការបង់ថ្លៃសេវា, ការញែកសំរាម សំណល់រឹងទីប្រជុំជនសម្រាប់ធ្វើការកែច្នៃ និងសម្អាត, ប្រមូលសំរាម សំណល់រឹងទីប្រជុំជនទុកដាក់នៅចំណុចប្រមូលផ្តុំក្នុងសហគមន៍ និងក្នុងមូលដ្ឋានរបស់ខ្លួនសម្រាប់ធ្វើការ

ដឹកជញ្ជូនចេញ

- ផ្សារភ្ជាប់បញ្ហានេះ រដ្ឋបាលថ្នាក់ក្រោមជាតិ, អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធដទៃទៀត នៅមូលដ្ឋានអាចដើរតួនាទីសំខាន់ក្នុងការអប់រំ និងជំរុញឱ្យសាធារណជន និងសហគមន៍មូលដ្ឋាន ចូលរួមអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនឱ្យកាន់តែល្អប្រសើរឡើងថែមទៀត ។

### ៩.៦- ទំនាក់ទំនងជាមួយសហគមន៍អន្តរជាតិ

- ស្ថាប័នរាជរដ្ឋាភិបាល (ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) ត្រូវបង្កើនទំនាក់ទំនងឱ្យបានល្អ ជាមួយសហគមន៍អន្តរជាតិនៅក្នុងវិស័យកិច្ចគាំពារបរិស្ថាន ដើម្បីឱ្យឆ្លើយតបទៅនឹងគោលដៅ អភិវឌ្ឍសហសវត្សរ៍
- ការបង្កើត និងធ្វើឱ្យប្រសើរឡើងនូវបណ្តាញការងារជាមួយសហគមន៍អន្តរជាតិ និងប្រទេស នៅក្នុង តំបន់ គឺមានសារសំខាន់ណាស់ក្នុងការទទួលយកនូវការផ្ទេរបច្ចេកវិទ្យាថ្មីៗ សម្រាប់ការអនុវត្ត កម្មវិធីកាត់បន្ថយការប្រើប្រាស់ និងការកែច្នៃនៃសំរាម សំណល់រឹងទីប្រជុំជន
- កង្វះធនធានមនុស្ស និងថវិកា គឺជាបញ្ហាចម្បងដែលចាំបាច់ត្រូវស្វែងរកការគាំទ្រពីសហគមន៍ អន្តរជាតិ និងម្ចាស់ជំនួយផ្សេងទៀតដើម្បីអនុវត្តនូវសកម្មភាពទាំងនេះ ។

## ១០- យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ដើម្បីលើកកម្ពស់ប្រសិទ្ធភាពក្នុងការអនុវត្តគោលនយោបាយស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹង ទីប្រជុំជន ២០២០-២០៣០ ចាំបាច់ត្រូវមានយន្តការសម្រាប់តាមដានត្រួតពិនិត្យ, កែតម្រូវ និងការវាយតម្លៃ លើការអនុវត្តគោលនយោបាយនេះ ដើម្បីវិភាគលើលទ្ធផលនៃការប្រតិបត្តិ, បូកសរុបលទ្ធផលការងារដែល សម្រេចបាន បញ្ហាប្រឈមនានា និងផលប៉ះពាល់នានា ព្រមទាំងលើកទិសដៅអនុវត្តបន្ត ។ ការវាយតម្លៃ ប្រសិទ្ធភាពក្នុងការអនុវត្តគោលនយោបាយនេះត្រូវធ្វើឡើង ដោយផ្តោតលើ៖

- គោលដៅ និងយុទ្ធសាស្ត្រនៃគោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- សូចនាករនៃផែនការសកម្មភាពក្នុងការអនុវត្តគោលនយោបាយគ្រប់គ្រងសំរាម សំណល់រឹង ទីប្រជុំជន
- ការចូលរួមរបស់អ្នកទទួលសេវា, អ្នកផ្តល់សេវា និងភាគីពាក់ព័ន្ធ
- របាយការណ៍វឌ្ឍនភាព និងការពិនិត្យឡើងវិញស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- លទ្ធផលដែលទទួលបានត្រូវយកជាមូលដ្ឋានសម្រាប់ធ្វើការប្រៀបធៀប និងកែលម្អការងារ ប្រតិបត្តិដែលនៅខ្វះចន្លោះ ការរកដំណោះស្រាយនៃបញ្ហាប្រឈមនានា ដើម្បីរៀបចំផែនការ ការងារថ្មីឱ្យបានសមស្រប
- ផលប្រយោជន៍ដែលទទួលបានពីការអនុវត្តគោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹង ទីប្រជុំជន ២០២០-២០៣០ ។

**១០.១- ថ្នាក់ជាតិ**

- គណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន តាមដាន, ត្រួតពិនិត្យ, កែតម្រូវ, វាយតម្លៃគោលដៅយុទ្ធសាស្ត្រ និងការអនុវត្តផែនការសកម្មភាពធៀបនឹងចំណុចដៅក្នុងការអនុវត្តវិធានការ នៃគោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ២០២០-២០៣០ (ឧបសម្ព័ន្ធ១) ។
- គណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជូនគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**១០.២- ថ្នាក់ក្រោមជាតិ**

ក្នុងការតាមដាន, ត្រួតពិនិត្យ, កែតម្រូវ និងវាយតម្លៃការអនុវត្តគោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រដ្ឋបាលថ្នាក់ក្រោមជាតិមានភារកិច្ចដូចខាងក្រោម៖

- រដ្ឋបាលរាជធានី, ខេត្ត ត្រួតពិនិត្យ និងតាមដានដំណើរការនៃការផ្តល់សេវាសម្អាត, ប្រមូល និងដឹកជញ្ជូន សំរាម សំណល់រឹងទីប្រជុំជន និងសហការត្រួតពិនិត្យ កំណត់ទីតាំងរៀបចំទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយ អនាម័យ ព្រមទាំងការទុកដាក់សំរាម សំណល់រឹងទីប្រជុំជនជាលក្ខណៈអន្តរក្រុង និងស្រុក (ទីលានប្រើរួមគ្នា) ។
- រដ្ឋបាលថ្នាក់រាជធានី, ក្រុង និងស្រុក មានតួនាទីត្រួតពិនិត្យ និងតាមដានការអនុវត្តផ្ទាល់លើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនអនុលោមតាមយុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃគោលនយោបាយស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ២០២០-២០៣០ សំដៅធានាឱ្យការអភិវឌ្ឍនៅក្នុងមូលដ្ឋានរបស់ខ្លួន ប្រកបដោយចីរភាព ។

## ១១- សេចក្តីសន្និដ្ឋាន

គោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ២០២០-២០៣០ មានសារសំខាន់ណាស់ក្នុងការធានានូវតុល្យភាពរវាងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងកិច្ចគាំពារបរិស្ថាន ។ ការអនុវត្តវិធានការគោលនយោបាយនេះ អាចជួយកាត់បន្ថយបាននូវបរិមាណសំរាម សំណល់រឹងទីប្រជុំជនដែលមានការកើនឡើងជារៀងរាល់ឆ្នាំ តាមរយៈការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន តាមវិធានការចម្រុះ ដែលសំរាម សំណល់រឹងទីប្រជុំជនភាគច្រើន អាចត្រូវបានយកមកប្រើប្រាស់ ឬកែច្នៃ ដើម្បីជួយបង្កើនអាយុកាលនៃទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន និង ធានាបាននូវអនាម័យ និងសុវត្ថិភាពបរិស្ថាន ។ ស្របពេលជាមួយគ្នានេះ គោលនយោបាយស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ២០២០-២០៣០ ក៏បានជួយលើកតម្កើងសោភ័ណភាពទីប្រជុំជនរាជធានី, ក្រុង និងស្រុក ឱ្យកាន់តែស្រស់បំព្រង ដែលសកម្មភាពទាំងនេះឆ្លើយតបទៅនឹងទស្សនវិស័យស្តីពីនិរន្តរភាពបរិស្ថានទីក្រុងដែលបាន និងកំពុងអនុវត្តក្នុងតំបន់អាស៊ាន ក៏ដូចជាការចូលរួមចំណែកដល់ការងារប្រឡងប្រណាំងទីក្រុងស្អាតនៅថ្នាក់ជាតិផងដែរ ។

តាមរយៈការអនុវត្តគោលនយោបាយនេះ រាជរដ្ឋាភិបាលរំពឹងថាចាប់ពីពេលនេះ រហូតដល់ឆ្នាំ ២០៣០ ខាងមុខ សំរាម សំណល់រឹងទីប្រជុំជនគ្រប់ប្រភេទទាំងអស់នឹងត្រូវបានសម្អាត, ប្រមូល, ដឹកជញ្ជូន, ប្រើប្រាស់ឡើងវិញ និងកែច្នៃ ព្រមទាំងធ្វើប្រព្រឹត្តិកម្ម តាមបច្ចេកវិទ្យាប្រកបដោយអនាម័យ និងសុវត្ថិភាព

បរិស្ថាន ។ ជាមួយគ្នានេះ ក៏នឹងជួយលើកតម្កើងនូវសុខុមាលភាពប្រជាពលរដ្ឋ និងលើកកម្ពស់សោភ័ណភាពទីប្រជុំជនរាជធានី, ខេត្ត និងស្រុក ឱ្យកាន់តែមានភាពទាក់ទាញថែមទៀត ជាពិសេសលើកស្ទួយកិត្យានុភាពជាតិស្របតាមពាក្យស្លោក **"កម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ"** ។

# សទ្ធានុក្រម

១. **ទីប្រជុំជន** សំដៅដល់រាជធានី, ទីរួមក្រុង, ទីរួមស្រុក លំនៅឋានប្រមូលផ្តុំ និងទីប្រជុំជនផ្សេងទៀត ដែលមានប្រជាជនរស់នៅលើស ៥០០០ នាក់ឡើងទៅ ។

២. **សំរាម** សំដៅដល់របស់របរប្រើប្រាស់, សម្ភារផលិតផលដែលបានបន្សល់ ឬបង្កើតពីសកម្មភាព និងជីវភាពផ្ទាល់របស់មនុស្សប្រចាំថ្ងៃដែលមិនមានផ្ទុកសារជាតុពុល ឬសំណល់គ្រោះថ្នាក់ ។

៣. **សំណល់រឹងទីប្រជុំជន** សំដៅដល់សំណល់រឹងដែលបានបន្សល់ ឬបង្កើតពីសកម្មភាពអាជីវកម្ម ឬសេវាកម្មដែលមិនមានផ្ទុកសារជាតុពុល ឬសំណល់គ្រោះថ្នាក់ ។

៤. **គោលការណ៍ ៣អ៊េ** សំដៅដល់ការកាត់បន្ថយ ការប្រើប្រាស់ និងការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន

៥. **ការទាញយកធនធាន** សំដៅដល់សកម្មភាពជម្រើស ឬប្រើប្រាស់សំរាម សំណល់រឹងទីប្រជុំជន ធ្វើជាជីកំប៉ុស្តិ៍ កែច្នៃទាញយកថាមពល ឬសារប្រយោជន៍នានា ។

៦. **ការកែច្នៃ** សំដៅដល់សកម្មភាព ឬដំណើរការបំបែក ឬបំប្លែងសំរាម សំណល់រឹងទីប្រជុំជនទៅជាវត្ថុធាតុដើមសម្រាប់បម្រើការផលិតឡើងវិញ ។

៧. **ការប្រើប្រាស់ឡើងវិញ** សំដៅដល់ការជម្រើសសំរាម សំណល់រឹងទីប្រជុំជនដែលអាចប្រើប្រាស់សារជាថ្មីឡើងវិញដោយគ្រាន់តែឆ្លងកាត់ការលាងសម្អាត ឬការជួសជុលដោយនៅរក្សាទ្រង់ទ្រាយដើម ។

៨. **ការញែក** សំដៅដល់ការបែងចែកទៅតាមប្រភេទនៃសំរាម សំណល់រឹងទីប្រជុំជននៅនឹងប្រភពបង្កើតសម្រាប់គោលបំណងទាញយកធនធាន ឬធានាសុវត្ថិភាពក្នុងការយកទៅចាក់នៅទីលាន ។

៩. **ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន** សំដៅដល់ទីកន្លែងដែលអាជ្ញាធរបានកំណត់ ឬរៀបចំតាមវិធានការសុវត្ថិភាពបរិស្ថានសម្រាប់ការទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ។

១០. **ការធ្វើប្រព្រឹត្តកម្ម** សំដៅដល់សកម្មភាព ឬវិធានការនៅក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដែលរួមមាន៖

- ក). ការបន្ថយទំហំ ឬបរិមាណសំរាម សំណល់រឹងទីប្រជុំជនមុនយកទៅទុកដាក់នៅទីលាន ដូចជាការដោះបំបែក, ការកិនកម្ទេច, ការរំលាយ ឬការដុតនៅក្នុងឡ ជាដើម ។
- ខ). ការដកយក ឬការកម្ទេចចោលជាតិពុល, សារជាតុគ្រោះថ្នាក់ ឬភ្នាក់ងារចម្លងជំងឺ ដែលមាននៅក្នុងសំរាម សំណល់រឹងទីប្រជុំជន មុនការយកទៅចាក់នៅទីលាន ។

# ឧបសម្ព័ន្ធ ១ ផែនការគោលនយោបាយស្ដីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

| ប្រភេទនៃផែនការ | បញ្ហាត្រូវដោះស្រាយ | ផែនការគោលនយោបាយ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|
| **ពាក់ព័ន្ធការរៀបចំក្របខណ្ឌច្បាប់ លិខិតបទដ្ឋានគតិយុត្ត លើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន** | | | |
| *ផែនការរយៈពេលខ្លី* | *ការធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមផែនការចម្រុះ និងការបង្កើនប្រសិទ្ធភាព និងការពង្រីកវិសាលភាពនៃការផ្ដល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន* | - រៀបចំលិខិតបទដ្ឋានបច្ចេកទេសស្ដីពីប្រតិបត្តិការសម្អាត, ប្រមូល, ដឹកជញ្ជូន, ទុកដាក់ និងការរៀបចំបង្កើតស្ថានីយផ្ទេរ ស្ថានីយទាញយកធនធាន និងកែច្នៃ និងប្រតិបត្តិការទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនប្រកបដោយអនាម័យ និងសុវត្ថិភាពបរិស្ថាន<br>- រៀបចំលិខិតបទដ្ឋានបច្ចេកទេសស្ដីពីដំណើរការអនុវត្តប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមផែនការចម្រុះ<br>- រៀបចំគោលការណ៍ណែនាំអំពីនីតិវិធីការធ្វើសារពើភណ្ឌសំរាម សំណល់រឹងទីប្រជុំជន ដើម្បីប៉ាន់ស្មានបរិមាណ និងសមាសភាពសំរាម សំណល់រឹងដែលបានបង្កើត និងកំណត់កាលានុវត្តភាពដើម្បីកាត់បន្ថយការប្រើប្រាស់ និងកែច្នៃ<br>- រៀបចំគោលការណ៍ណែនាំអំពីការរៀបចំផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន<br>- រៀបចំកំណត់ថ្លៃសេវាដោយផ្អែកតាមប្រភេទអាជីវកម្ម, ទីតាំង, កម្រិតប្រាក់ចំណូល និងបរិមាណសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើត ។ | - គណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងបរិស្ថាន<br>- ក្រសួងមហាផ្ទៃ (គជអប) |
| | | - រៀបចំផែនការសកម្មភាព ផែនការប្រតិបត្តិការ ធ្វើសារពើភណ្ឌបរិមាណសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតប្រចាំថ្ងៃ និងការគ្រប់គ្រងទិន្នន័យ ។ល។<br>- រៀបចំគំរូឯកសារដេញថ្លៃសម្រាប់កិច្ចសន្យារាប់បញ្ចូលទាំងសូចនាករសមិទ្ធកម្មសម្រាប់វិស័យឯកជន<br>- កំណត់កម្មវិធី និងវិធានការលុបបំបាត់ការបោះចោលសំរាម សំណល់រឹងទីប្រជុំជនរាយប៉ាយនៅតាមទីសាធារណៈក្នុងដែនសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន<br>- កំណត់ថ្លៃសេវា និងការប្រមូលថ្លៃសេវាដែលបង់ដោយប្រជាពលរដ្ឋតាមគេហដ្ឋាន និងមជ្ឈមណ្ឌលពាណិជ្ជកម្មដោយគិតទៅតាមប្រភេទគេហដ្ឋាន និងប្រភេទ និងទំហំអាជីវកម្ម<br>- ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តថ្នាក់ក្រោមជាតិ សម្រាប់អនុវត្តវិធានការច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន ។ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងបរិស្ថាន<br>- រដ្ឋបាលរាជធានី ខេត្ត<br>- រដ្ឋបាលក្រុង ស្រុក |

| | | | |
|---|---|---|---|
| **វិធានការរយៈពេលមធ្យម** | | - រៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីជំរុញការកាត់បន្ថយការបង្កើតសំរាម សំណល់រឹងទីប្រជុំជន ជាពិសេសសំណល់ប្លាស្ទិកជាដើម ដើម្បីឈានទៅលុបបំបាត់ការប្រើប្រាស់ថង់ និងសម្ភារប្លាស្ទិកដែលប្រើបានតែមួយលើក ឬដែលអាចប្រើសម្ភារផ្សេងជំនួសបាន និងប្រែក្លាយសំរាម សំណល់រឹងទីប្រជុំជនទាំងនោះឱ្យមានតម្លៃសេដ្ឋកិច្ច<br>- រៀបចំលិខិតបទដ្ឋានបច្ចេកទេសពាក់ព័ន្ធនឹងការរៀបចំទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនប្រកបដោយអនាម័យ និងសុវត្ថិភាពបរិស្ថាន និងប្រតិបត្តិការទីលានចាក់សំរាម សំណល់រឹងទីប្រជុំជន អាជ្ញាបណ្ណប្រតិបត្តិការទីលាន, ការប្រមូលសំណាកគំរូ និងការធ្វើវិភាគសមាសភាគសំរាម សំណល់រឹងទីប្រជុំជន ព្រមទាំងប្រព័ន្ធរាយការណ៍ និងការគ្រប់គ្រងទិន្នន័យ<br>- រៀបចំផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពតាមគោលការណ៍ ៣អ៊េៈ ការកាត់បន្ថយ ការប្រើប្រាស់ និង ការកែច្នៃ ។ | - គណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងបរិស្ថាន<br>- ក្រសួងមហាផ្ទៃ (គជអប) |
| | | - ធ្វើការកែសម្រួលកម្រៃថ្មីលើសេវាសម្អាត, ប្រមូល, ដឹកជញ្ជូន និងទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅ ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន<br>- ការរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មាន និងទិន្នន័យដែលអាចជឿទុកចិត្តបានអំពីបរិមាណសមាសភាពសំរាម សំណល់រឹងទីប្រជុំជន សម្រាប់ការធ្វើសេចក្តីសម្រេចចិត្តក្នុងការរៀបចំយន្តការបង្កើតការផ្តល់សេវាសម្អាត, ប្រមូល, ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន<br>- ពង្រឹងការអនុវត្តវិធានការច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន និងការអនុវត្តវិធានការពិន័យអន្តរការណ៍លើបទល្មើសពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន ។ | - ក្រសួងបរិស្ថាន<br>- រដ្ឋបាលរាជធានី ខេត្ត<br>- រដ្ឋបាលខេត្ត ក្រុង និង<br>- វិស័យឯកជន |
| **វិធានការរយៈពេលវែង** | | - រៀបចំលិខិតបទដ្ឋាន គោលការណ៍ណែនាំបច្ចេកទេស និងយន្តការនានាដែលនៅមានភាពខ្វះចន្លោះ ដើម្បីអនុវត្តគោលនយោបាយនេះឱ្យកាន់តែមានប្រសិទ្ធភាព<br>- រៀបចំផែនការយុទ្ធសាស្ត្រ ស្តីពីគំនិតផ្តួចផ្តើម "សំណល់សូន្យ " "ZeroWaste"<br>- រៀបចំលិខិតបទដ្ឋានគតិយុត្តិទាំងកម្រិតជាតិ និងកម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមរបស់វិស័យឯកជន រួមបញ្ចូលនូវការទទួលខុសត្រូវរបស់ផលិតករលើសំណល់ពីការប្រើប្រាស់ផលិតផលរបស់ខ្លួន (Extended Producer Responsibility) | - គណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងបរិស្ថាន<br>- ក្រសួងមហាផ្ទៃ (គជអប) |

| | | | |
|---|---|---|---|
| | | - ពិនិត្យ និងរៀបចំកែសម្រួលកម្រៃសេវាសម្អាត, ប្រមូល, ដឹកជញ្ជូន និងទុកដាក់សំរាម សំណល់រឹងទីប្រជុំជន នៅទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ដោយផ្អែកលើបរិមាណសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើត | |
| | | - បន្តពង្រឹងការអនុវត្តវិធានការ, ច្បាប់, លិខិតបទដ្ឋានគតិយុត្តជាធរមាន<br>- ជំរុញការអនុវត្តវិធានការកាត់បន្ថយការប្រើប្រាស់ថង់, សម្ភារប្លាស្ទិក និងបង្កើនការប្រើប្រាស់ផលិតផលផ្សេងជំនួស ។ | - ក្រសួងបរិស្ថាន<br>- រដ្ឋបាលរាជធានី ខេត្ត<br>- រដ្ឋបាលក្រុង ស្រុក |
| **ពាក់ព័ន្ធការធ្វើឱ្យប្រសើរឡើងសេវាសម្អាត, ប្រមូល, ដឹកជញ្ជូន, ប្រព្រឹត្តិកម្ម និងទីលានប្រកបដោយអនាម័យ** | | | |
| ***ទិសដៅរយៈពេលខ្លី*** | ***ការជំរុញនិងលើកទឹកចិត្តការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន របស់រដ្ឋបាលថ្នាក់ក្រោមជាតិ*** | - ជំរុញការអនុវត្តកំណែទម្រង់ពីការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន<br>- រៀបចំផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំ សម្រាប់ប្រតិបត្តិការសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន<br>- សិក្សាជម្រើសគម្រោងការបំប្លែងសំរាម សំណល់រឹងទីប្រជុំជនទៅជាថាមពលដោយត្រូវសិក្សាពីជម្រើសបច្ចេកវិទ្យានានា ដែលសមស្របព្រមទាំងធានាដល់និរន្តរភាពនៃប្រតិបត្តិការគម្រោង<br>- សិក្សាពីសមិទ្ធលទ្ធភាពការវិនិយោគការបំប្លែងសំរាម សំណល់រឹងទីប្រជុំជនជាថាមពល ។ | - គណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងបរិស្ថាន<br>- ក្រសួងមហាផ្ទៃ (គជអប)<br>- ក្រសួងរ៉ែ និងថាមពល<br>- អគ្គិសនីកម្ពុជា |
| | | - ពង្រឹងភាពជាម្ចាស់នៃការទទួលខុសត្រូវរបស់រដ្ឋបាលរាជធានី, ក្រុង និងស្រុក ក្នុងការអនុវត្តឱ្យបានពេញលេញនូវមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលបានផ្ទេរពីថ្នាក់ជាតិ<br>- ជំរុញឱ្យមានការរៀបចំអង្គភាព ឬការិយាល័យចំណុះរដ្ឋបាលរាជធានី, ក្រុង និងស្រុកក្នុងការទទួលខុសត្រូវអនុវត្តការផ្ទេរមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន<br>- ពង្រឹងភាពជាម្ចាស់ក្នុងការប្រមូលចំណូល និងការទូទាត់ថ្លៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដើម្បីពង្រឹងប្រសិទ្ធភាព និងពង្រីកវិសាលភាពការផ្តល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន<br>- រៀបចំយន្តការបង្កើតសេវាសម្អាត, ប្រមូល, ដឹកជញ្ជូន និងទុកដាក់សំរាម សំណល់រឹងទីប្រជុំជន នៅទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន<br>- ផ្តើមអនុវត្តកម្មវិធីញែកសំរាម សំណល់រឹងទីប្រជុំជននៅនឹងប្រភពបង្កើតសំរាម សំណល់រឹងទីប្រជុំជន និងដោយមានការដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនទាំងនេះ ដាច់ដោយឡែកពីគ្នា | - រដ្ឋបាលរាជធានី ខេត្ត<br>- រដ្ឋបាលក្រុង ស្រុក<br>- វិស័យឯកជន |

| | | | |
|---|---|---|---|
| | | - កំណត់កម្មវិធី និងវិធានការលុបបំបាត់ការចោលសំរាម សំណល់រឹងទីប្រជុំជន ដែលបានបោះចោល និងនៅរាយប៉ាយតាមទីសាធារណៈ ។ | |
| ***ទិសដៅរយៈពេលមធ្យម*** | | - រៀបចំឱ្យមានទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនប្រកបដោយអនាម័យ និងសុវត្ថិភាពបរិស្ថាន ដោយការជ្រើសរើសទីតាំងសាងសង់ទីលានត្រូវរៀបចំជាលក្ខណៈតំបន់ ដែលអាចប្រើប្រាស់រួមសម្រាប់រាជធានី, ក្រុង, ស្រុក ឬតំបន់ផ្សេងទៀតនៅជុំវិញ<br>- បំពាក់ឡដុតសំរាម សំណល់រឹងទីប្រជុំជនខ្នាតតូចដែលមានបច្ចេកទេសត្រឹមត្រូវ និងមិនបង្កផលប៉ះពាល់ដល់ការបំពុលបរិស្ថាន សម្រាប់ទីប្រជុំជនដែលមានបរិមាណសំរាម សំណល់រឹងទីប្រជុំជនតិចតួច<br>- សិក្សាជម្រើសគម្រោងការបំប្លែងសំរាម សំណល់រឹងទីប្រជុំជនទៅជាថាមពល ដោយត្រូវសិក្សាពីជម្រើសបច្ចេកវិទ្យានានាដែលសមស្រប ព្រមទាំងធានាដល់និរន្តរភាពនៃប្រតិបត្តិការគម្រោង<br>- ជំរុញការអនុវត្តវិធានការ, ច្បាប់, លិខិតបទដ្ឋានគតិយុត្តជាធរមាន និងអនុវត្តវិធានការពិន័យអន្តរការណ៍លើបទល្មើសពាក់ព័ន្ធនឹងការចោល ឬទុកដាក់សំរាម សំណល់រឹងទីប្រជុំជនមិនបានត្រឹមត្រូវ ។ | - គណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងបរិស្ថាន<br>- ក្រសួងមហាផ្ទៃ (គជអប)<br>- ក្រសួងរ៉ែ និងថាមពល<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- អគ្គិសនីកម្ពុជា |
| | | - ជំរុញដាក់ឱ្យប្រើប្រាស់ប្រព័ន្ធវៃឆ្លាតសម្រាប់គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន( Artificial Intelligent Municipal Solid Waste Management System)<br>- ពង្រឹង និងពង្រីកសមត្ថភាពសម្អាត, ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនឱ្យបានទូលំទូលាយស្របតាមតម្រូវការជាក់ស្តែងនៅមូលដ្ឋាន ជាមួយនឹងការរៀបចំឱ្យមានធុងសំរាមនៅតាមទីសាធារណៈ, កន្លែងកំសាន្ត, រមណីយដ្ឋាន និងតំបន់ទេសចរណ៍នានា ដោយធ្វើការបែងចែកធុងសំរាមជាប្រភេទផ្សេងៗគ្នាតាមភាពជាក់ស្តែង<br>- ពង្រីកវិសាលភាពការប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន ដោយវិភាជថវិកាឱ្យដល់រដ្ឋបាលមូលដ្ឋានគោលដៅ<br>- ពង្រីកវិសាលភាពការអនុវត្តកម្មវិធីញែកសំរាម សំណល់រឹងទីប្រជុំជននៅនឹងប្រភពបង្កើតសំរាម សំណល់រឹងទីប្រជុំជន និងដោយមានការដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនទាំងនេះដាច់ដោយឡែកពីគ្នា ។ | - រដ្ឋបាលរាជធានី ខេត្ត<br>- រដ្ឋបាលក្រុង ស្រុក<br>- វិស័យឯកជន |

| | | | |
|---|---|---|---|
| ***ទិសដៅការរយៈពេលវែង*** | | - វិនិយោគសាងសង់ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនសម្រាប់រាជធានី, ក្រុង និងស្រុក<br>- លុបបំបាត់ និង/ឬ កែលម្អទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលមានស្រាប់ និងកំពុងទទួលរងបំពុលបរិស្ថានតាមរយៈការធ្វើឱ្យប្រសើរឡើង និង/ឬ បិទទីកន្លែងទាំងនោះដើម្បីធានាសុវត្ថិភាព<br>- វិនិយោគសាងសង់ឡដុតសំណល់ ដើម្បីទាញយកថាមពលអគ្គិសនី សម្រាប់រាជធានីភ្នំពេញ និងបណ្តាទីក្រុងដែលមានសក្តានុពល និងពុំមានទីលានទុកដាក់ចាក់សំរាម សំណល់រឹងទីប្រជុំជន<br>- កែសម្រួលថ្លៃសេវាសម្អាត ,ប្រមូល ,ដឹកជញ្ជូន និងទុកដាក់សំរាម សំណល់រឹងនៅទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដោយផ្អែកលើបរិមាណនៃការបង្កើតសំរាម សំណល់រឹងទីប្រជុំជន<br>- អភិវឌ្ឍន៍បច្ចេកវិទ្យាទំនើប ដូចជា៖<br>+ បំប្លែងសំរាម សំណល់រឹងជាឥន្ធនៈរាវ (Converting municipal solid wastes to liquid fuel)<br>+ ការសិក្សាពីជម្រើសបច្ចេកវិទ្យា pyrolysis និងជីវឧស្ម័ន gasification | - គណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន<br>- ក្រសួងបរិស្ថាន<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- ក្រសួងធនធានទឹក និងឧតុនិយម<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ និង<br>- វិស័យឯកជន |
| | | - ប្រើប្រាស់បច្ចេកវិទ្យា នវានុវត្តន៍ថ្មីៗ ដែលធានាទាំងប្រសិទ្ធភាពគុណភាព និងតម្លៃសមស្រប សម្រាប់ការធ្វើឱ្យកាន់តែប្រសើរឡើងនូវសេវាសម្អាត, ប្រមូល, ដឹកជញ្ជូន និងទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយអនាម័យ និងសុវត្ថិភាពបរិស្ថាន<br>- អនុវត្តពេញលេញនូវការអនុវត្តកម្មវិធីញែកសំរាម សំណល់រឹងទីប្រជុំជននៅនឹងប្រភពបង្កើតសំរាម សំណល់រឹងទីប្រជុំជន និងដោយមានការដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនទាំងនេះ ដាច់ដោយឡែកពីគ្នា<br>- ពង្រឹងប្រសិទ្ធភាពការអនុវត្តវិធានការ, ច្បាប់, លិខិតបទដ្ឋានគតិយុត្តជាធរមាន ដែលពាក់ព័ន្ធនឹងសកម្មភាពល្មើសលើការចោលសំរាម សំណល់រឹងទីប្រជុំជន មិនបានត្រឹមត្រូវតាមការកំណត់របស់រដ្ឋបាលមូលដ្ឋាន ។ | - រដ្ឋបាលរាជធានី ខេត្ត<br>- រដ្ឋបាលក្រុង ស្រុក<br>- វិស័យឯកជន |
| **ពាក់ព័ន្ធការអនុវត្តកម្មវិធីកាត់បន្ថយ ប្រើប្រាស់ឡើងវិញ កែច្នៃនិងទាញយកធនធានពីសំរាម សំណល់រឹងប្រជុំជន** | | | |
| ***ទិសដៅការរយៈពេលខ្លី*** | ***ការកំណត់ជម្រើសនៃបច្ចេក-វិទ្យាដែលអាចអនុវត្តបានស្រប តាមស្ថានភាពជាក់ស្តែង និង*** | - រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងព័ត៌មាន ព្រមទាំងធ្វើបច្ចុប្បន្នភាពអំពីបរិមាណ និងសមាសភាគសំរាម សំណល់រឹងទីប្រជុំជន | - គណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន<br>- ក្រសួងបរិស្ថាន |

| | | | |
|---|---|---|---|
| | ***ការជំរុញការអនុវត្តកម្មវិធីកាត់បន្ថយការបង្កើតសំរាម សំណល់រឹងទីប្រជុំជន*** | - បណ្តុះបណ្តាលបច្ចេកទេស និងការអភិវឌ្ឍវិជ្ជាជីវៈពាក់ព័ន្ធនឹងវិធីសាស្ត្រគ្រប់ជ្រុងជ្រោយ ក្នុងការអភិវឌ្ឍការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការទាញយកធនធានឡើងវិញ<br>- ផ្តល់ការគាំទ្របច្ចេកទេស និងការកៀរគរថវិកាពីប្រភពនានាដើម្បីពង្រឹងប្រសិទ្ធភាពការផ្តល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន<br>- លើកទឹកចិត្តដល់វិស័យឯកជនឱ្យចូលរួមបង្កើតទីតាំងកែច្នៃ និងទាញយកធនធានឡើងវិញ<br>- ជំរុញការអភិវឌ្ឍឧស្សាហកម្មដីកំប៉ុស្តិ៍ និង/ឬ ជីវឧស្ម័នដោយប្រើបច្ចេកវិទ្យាសមស្រប<br>- ពង្រឹងអភិបាលកិច្ចល្អក្នុងគ្រប់យន្តការនានាទាក់ទងនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន<br>- ដាក់បញ្ចូលកម្មវិធីញែកសំរាម សំណល់រឹងទីប្រជុំជននៅតាមប្រភពបង្កើតសំរាម សំណល់រឹងទីប្រជុំជន និងដោយមានការដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនទាំងនេះ ដាច់ដោយឡែកពីគ្នា<br>- រៀបចំយុទ្ធនាការអប់រំផ្សព្វផ្សាយអំពីការប្រើប្រាស់សម្ភារវេចខ្ចប់តាមបែបបុរាណ<br>- លើកទឹកចិត្តអ្នកផលិតសម្ភារវេចខ្ចប់ដែលមិនមែនជាប្លាស្ទិក និងអ្នកប្រើប្រាស់<br>- រៀបចំគម្រោងអនុវត្តគំរូសម្រាប់ការប្រើប្រាស់ថង់បរិស្ថានជំនួសថង់ប្លាស្ទិកនៅតាមទីផ្សារទំនើប, មជ្ឈមណ្ឌលពាណិជ្ជកម្ម ជាដើម ។ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងទេសចរណ៍<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- រដ្ឋបាលរាជធានី ខេត្ត<br>- រដ្ឋបាលក្រុង ស្រុក<br>- អង្គការមិនមែនរដ្ឋាភិបាល<br>- វិស័យឯកជន |
| ***ទិសដៅរយៈពេលមធ្យម*** | | - បង្កើតវិធីសាស្ត្រគ្រប់ជ្រុងជ្រោយក្នុងការអភិវឌ្ឍកម្មវិធីកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ ការកែច្នៃ និងការទាញយកធនធានពីសំរាម សំណល់រឹងទីប្រជុំជន<br>- អនុវត្តវិធានការរឹតបន្តឹងការប្រើប្រាស់ថង់ សម្ភារប្លាស្ទិកមួយចំនួន ពិសេសប្រភេទប្លាស្ទិកដែលប្រើតែម្តងរួចបោះចោល<br>- រៀបចំបង្កើតឱ្យមានទីតាំងកែច្នៃសំរាម សំណល់រឹងទីប្រជុំជននៅតាមមូលដ្ឋានរាជធានី, ខេត្ត, ក្រុង និងស្រុក និងលើកទឹកចិត្តដល់ផ្នែកឯកជន និងអង្គការមិនមែនរដ្ឋាភិបាលឱ្យចូលរួមធ្វើសកម្មភាពក្នុង វិស័យកែច្នៃសំរាម សំណល់រឹងទីប្រជុំជន ព្រមទាំងលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលកែច្នៃចេញពី សំរាម សំណល់រឹងទីប្រជុំជន ដើម្បីឱ្យដំណើរការកែច្នៃអាចប្រព្រឹត្តទៅបានពេញលេញ<br>- ពង្រីកអត្រាការញែកសំរាម សំណល់រឹងទីប្រជុំជននិងដឹកជញ្ជូនដោយឡែកទៅតាមប្រភេទ និង<br>- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការថ្នាក់ជាតិ, តំបន់ និងអន្តរជាតិពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ។ | - គណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន<br>- ក្រសួងបរិស្ថាន<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងទេសចរណ៍<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- រដ្ឋបាលរាជធានី ខេត្ត<br>- រដ្ឋបាលក្រុង ស្រុក<br>- អង្គការមិនមែនរដ្ឋាភិបាល<br>- វិស័យឯកជន |

| | | | |
|---|---|---|---|
| ***ទិសដៅការរយៈពេលវែង*** | | - សិក្សាជម្រើសនៃការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ដែលធានាទាំងប្រសិទ្ធភាព, គុណភាព និងតម្លៃ សម្រាប់ការធ្វើឱ្យកាន់តែប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយអនាម័យ និងសុវត្ថិភាពបរិស្ថាន<br>- អនុវត្តបច្ចេកវិទ្យាទំនើបដើម្បីបង្កើនប្រសិទ្ធភាពការទាញយកធនធានឡើងវិញពីសំរាម សំណល់រឹងទីប្រជុំជន និង/ឬ បច្ចេកវិទ្យាការបំប្លែងសំរាម សំណល់រឹងទីប្រជុំជនជាថាមពល<br>- លុបបំបាត់ទាំងស្រុងការប្រើប្រាស់ថង់ និងសម្ភារប្លាស្ទិកដែលប្រើតែមួយលើកបោះចោល និងថង់ប្លាស្ទិកដែលមិនងាយពុកផុយ ជំនួសការប្រើប្រាស់ថង់បាយ ប្លាស្ទិក ឬសម្ភារផ្សេងទៀតដែលងាយពុកផុយ<br>- អនុវត្តវិធានការទប់ស្កាត់ការបង្កើត និងបង្កើនប្រសិទ្ធភាពការញែកគ្រប់ប្រភេទសំរាម សំណល់រឹងទីប្រជុំជន និងបង្កើនឧស្សាហកម្មកែច្នៃនិងការទាញយកធនធានឡើងវិញពីសំរាម សំណល់រឹងទីប្រជុំជន ឱ្យអស់លទ្ធភាព ។ | - គណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន<br>- ក្រសួងបរិស្ថាន<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងទេសចរណ៍<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- រដ្ឋបាលរាជធានី ខេត្ត<br>- រដ្ឋបាលក្រុង ស្រុក<br>- អង្គការមិនមែនរដ្ឋាភិបាល<br>- វិស័យឯកជន |
| **ពាក់ព័ន្ធការធ្វើឯកជនភាវូបនីយកម្មលើការផ្តល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន** | | | |
| ***ទិសដៅការរយៈពេលខ្លី*** | ***ការបង្កើតឱកាសវិនិយោគដល់វិស័យឯកជន លើការផ្តល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន*** | - ផ្តល់ឱកាសដល់វិស័យឯកជនចូលរួមក្នុងគ្រប់ខ្សែច្រវាក់នៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រួមមាន៖ ការសម្អាត, ប្រមូល និងដឹកជញ្ជូន ការធ្វើប្រព្រឹត្តិកម្ម, ការកែច្នៃ និងការទាញយកធនធានឡើងវិញ (ពីដើមខ្សែ ដល់ចុងខ្សែ)<br>- ការចូលរួមវិនិយោគពីវិស័យឯកជន អាចត្រូវបានញែកចេញជាផ្នែក ឬជាវិស័យ ដែលអាចឱ្យដៃគូផ្សេងៗបានចូលរួមក្នុងផ្នែកមួយ ឬច្រើននៃខ្សែច្រវាក់តាមរយៈការប្រកួតប្រជែងប្រកបដោយតម្លាភាព និងប្រសិទ្ធភាព<br>- ជំរុញឱ្យមានការចូលរួមឱ្យបានច្រើនពីសំណាក់ក្រុមហ៊ុនប្រមូលសំរាម សំណល់រឹងទីប្រជុំជន ដើម្បីឱ្យមានការប្រកួតប្រជែងគ្នាសម្រាប់ទីក្រុងធំៗ (បរិមាណ និងដង់ស៊ីតេប្រជាពលរដ្ឋខ្ពស់)<br>- ផ្តើមយុទ្ធនាការអនុវត្តកម្មវិធីញែកសំរាម សំណល់រឹងទីប្រជុំជនទៅតាមប្រភេទ នៅតាមទីតាំងសំខាន់ៗ ជាអាទិ៍៖ អាគាររដ្ឋបាលសាធារណៈ, មជ្ឈមណ្ឌលពាណិជ្ជកម្ម, មណ្ឌលកំសាន្តសណ្ឋាគារ, រមណីយដ្ឋាន និងនៅតាមសហគមន៍ ។ល។ | - គណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងបរិស្ថាន<br>- ក្រសួងមហាផ្ទៃ (គជអប)<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- រដ្ឋបាលរាជធានី ខេត្ត<br>- រដ្ឋបាលក្រុង ស្រុក<br>- វិស័យឯកជន |

| | | | |
|---|---|---|---|
| | | - ជំរុញការអនុវត្តប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមវិធានការចម្រុះ ដើម្បីប្រែក្លាយសំរាម សំណល់រឹងទីប្រជុំជនជាតម្លៃសេដ្ឋកិច្ច ។ | |
| **វិធានការរយៈពេលមធ្យម** | | - ជំរុញ និងលើកទឹកចិត្តដល់វិស័យឯកជនចូលរួមវិនិយោគលើការបំប្លែងសំរាម សំណល់រឹងទីប្រជុំជន ជាថាមពល<br>- ជំរុញ និងលើកទឹកចិត្តវិស័យឯកជនឱ្យចូលរួមវិនិយោគក្នុងការកែច្នៃនិងទាញយកធនធានពីសំរាម សំណល់រឹងទីប្រជុំជន<br>- ជំរុញ និងលើកទឹកចិត្តដល់អង្គការមិនមែនរដ្ឋាភិបាលឱ្យចូលរួមធ្វើសកម្មភាពក្នុងវិស័យកែច្នៃសំរាម សំណល់រឹងទីប្រជុំជន ព្រមទាំងលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលកែច្នៃចេញពីសំណល់<br>- ជំរុញ និងលើកទឹកចិត្តការបង្កើតឧស្សាហកម្មកែច្នៃសំរាម សំណល់រឹងទីប្រជុំជន និងលើកទឹកចិត្តដល់ការប្រើប្រាស់ផលិតផលដែលបានមកពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជនឡើងវិញ<br>- លើកកម្ពស់កម្មវិធីកាត់បន្ថយការប្រើប្រាស់ថង់ និងសម្ភារប្លាស្ទិកប្រភេទមួយចំនួនដោយជំរុញការប្រើប្រាស់វត្ថុជំនួសដែលមិនបង្កផលប៉ះពាល់ដល់សុខភាពសាធារណៈ និងគុណភាពបរិស្ថាន<br>- បង្កើនកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីដើម្បីស្វែងរកជំនួយសម្រាប់ការផ្តល់ហិរញ្ញប្បទានដល់គម្រោងអភិវឌ្ឍន៍ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ។ | - គណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងបរិស្ថាន<br>- ក្រសួងមហាផ្ទៃ (គជអប)<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- រដ្ឋបាលរាជធានី ខេត្ត<br>- រដ្ឋបាលក្រុង ស្រុក<br>- វិស័យឯកជន |
| **វិធានការរយៈពេលវែង** | | - បង្កើតភាពជាដៃគូនិងលើកទឹកចិត្តដល់វិស័យឯកជនចូលរួមវិនិយោគលើការបំប្លែងសំរាម សំណល់រឹងទីប្រជុំជនទៅជាថាមពល<br>- ជំរុញ និងលើកទឹកចិត្តឱ្យមានការគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធ តាមរយៈការបង្កើតភាពជាដៃគូជិតស្និតដើម្បីធានាឱ្យការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដំណើរការប្រកបដោយប្រសិទ្ធភាព<br>- ជំរុញការចូលរួមអនុវត្តផែនការកាត់បន្ថយការបង្កើតសំរាម សំណល់រឹងទីប្រជុំជននៅនឹងប្រភពបង្កើត ជាពិសេសសំណល់ប្លាស្ទិក<br>- លើកកម្ពស់ការជំរុញ និងផ្តល់ឱកាសដល់វិស័យឯកជនប្រើប្រាស់នូវបច្ចេកវិទ្យាទំនើបតាមរយៈការបំពាក់នូវគ្រឿងបរិក្ខារស្វ័យប្រវត្តិកម្ម ដើម្បីសម្រួលដល់ការប្រតិបត្តិគម្រោង និងប្រើប្រាស់កម្លាំងពលកម្មតិច<br>- រួមអនុវត្តវិធានការលុបបំបាត់ការប្រើប្រាស់ថង់ និងសម្ភារប្លាស្ទិកមួយចំនួនដែលមិនចាំបាច់ និង | - គណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងបរិស្ថាន<br>- ក្រសួងមហាផ្ទៃ (គជអប)<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- រដ្ឋបាលរាជធានី ខេត្ត<br>- រដ្ឋបាលក្រុង ស្រុក |

| | | | |
|---|---|---|---|
| | | ជំរុញការប្រើប្រាស់ផលិតផលផ្សេងជំនួស<br>- បន្តកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីដើម្បីស្វែងរកជំនួយសម្រាប់ការផ្តល់ហិរញ្ញប្បទានដល់គម្រោងអភិវឌ្ឍន៍ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ។ | - វិស័យឯកជន |
| **ពាក់ព័ន្ធការអប់រំការផ្សព្វផ្សាយនិងការចូលរួមពីសាធារណជនលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន** | | | |
| ***ទិសដៅរយៈពេលខ្លី*** | ***លើកកម្ពស់ការអប់រំ, ការផ្សព្វផ្សាយ និងការជំរុញឱ្យមានការចូលរួមពីសាធារណជនអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន*** | - រៀបចំកម្មវិធីអប់រំ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដើម្បីលើកកម្ពស់ការធ្វើអនាម័យតាមគេហដ្ឋាន និងដើម្បីពង្រីកចំណេះដឹងសាធារណៈអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន<br>- អប់រំ និងផ្សព្វផ្សាយអំពីវិធានការច្បាប់ពាក់ព័ន្ធនឹងការចោលសំរាម សំណល់រឹងទីប្រជុំជន មិនបានត្រឹមត្រូវតាមការកំណត់របស់រដ្ឋបាលមូលដ្ឋាន<br>- លើកកម្ពស់ការអប់រំ និងការផ្សព្វផ្សាយតាមគ្រប់រូបភាពដល់សាធារណជនអំពីសារប្រយោជន៍នៃការញែកសំរាម សំណល់រឹងទីប្រជុំជន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ ព្រមទាំងលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន<br>- ផ្សព្វផ្សាយអំពីកាតព្វកិច្ចអ្នកប្រើប្រាស់សេវាសម្អាត, ប្រមូល, ដឹកជញ្ជូន និងទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ត្រូវបង់កម្រៃសេវា ។ | - គណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន<br>- ក្រសួងបរិស្ថាន<br>- ក្រសួងអប់រំ<br>- ក្រសួងព័ត៌មាន<br>- ក្រសួងទេសចរណ៍<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- អង្គការមិនមែនរដ្ឋាភិបាល<br>- វិស័យឯកជន |
| ***ទិសដៅរយៈពេលមធ្យម និងវែង*** | | - ដាក់បញ្ចូលកម្មវិធីអនាម័យបរិស្ថានទៅក្នុងកម្មវិធីសិក្សានៅតាមគ្រឹះស្ថានអប់រំ<br>- បន្តធ្វើការអប់រំ និងផ្សព្វផ្សាយអំពីវិធានការ, ច្បាប់, លិខិតបទដ្ឋានគតិយុត្តិ ពាក់ព័ន្ធនឹងការបោះចោលសំរាម សំណល់រឹងទីប្រជុំជន មិនបានត្រឹមត្រូវតាមការកំណត់របស់រដ្ឋបាលមូលដ្ឋាន<br>- បង្កើនការអប់រំ ផ្សព្វផ្សាយពីចំណេះដឹងសាធារណៈ ដើម្បីពង្រីកវិសាលភាពក្នុងអនុវត្តនូវកម្មវិធីនៃការកាត់បន្ថយ, ការកែច្នៃ និងការទាញយកធនធានពីសំរាម សំណល់រឹងទីប្រជុំជន<br>- លើកកម្ពស់ការធ្វើអនាម័យតាមគេហដ្ឋាន និងពង្រីកចំណេះដឹងសាធារណៈអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន<br>- ដឹកនាំអនុវត្តចលនាប្រឡងប្រណាំងទីក្រុងស្អាត ដើម្បីលើកកម្ពស់សោភ័ណភាព អនាម័យបរិស្ថានល្អនៅតាមបណ្តាទីប្រជុំជននានា នៃព្រះរាជាណាចក្រកម្ពុជាប្រកបដោយភាពទាក់ទាញ<br>- រៀបចំបង្កើតយន្តការប្រឡងប្រណាំង និងការលើកទឹកចិត្តនានាពាក់ព័ន្ធនឹងការប្រតិបត្តិល្អក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ។ | - គណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន<br>- ក្រសួងបរិស្ថាន<br>- ក្រសួងអប់រំ<br>- ក្រសួងព័ត៌មាន<br>- ក្រសួងទេសចរណ៍<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- អង្គការមិនមែនរដ្ឋាភិបាល<br>- វិស័យឯកជន |